# សិក្សាព្រះសូត្រ

## ភាគទី២



រៀបរៀងដោយ

[illegible]

[illegible] ប៊ុត សាវង្ស

# ពាក្យប្រារព្ធ

សៀវភៅ **សិក្សាព្រះសូត្រ** នេះ គ្រាន់តែជាជំនួយឱ្យមានចំណូលចិត្តក្នុងការអានព្រះត្រៃបិដក ដោយខ្ញុំព្រះករុណា ខ្ញុំបាទស្រង់ឈ្មោះតាមលំដាប់នៃព្រះសូត្រ ប្រារព្ធទីចារិក និងការគង់ប្រថាប់នៅនៃព្រះដ៏មានព្រះភាគ ព្រមដោយភិក្ខុសង្ឃ ហើយមានសេចក្ដីនៃព្រះធម៌ខ្លះ អត្ថន័យក្នុងព្រះអដ្ឋកថាខ្លះ គ្រាន់បានជាទីជ្រះថ្លាក្នុងការអាន ឬការស្ដាប់ ចម្រើននូវពុទ្ធានុស្សតិជាដើម ។

នៅចុងក្រោយអដ្ឋកថា **ទីឃនិកាយ** ឈ្មោះថា **សុមង្គលវិលាសិនី** មានការរំលឹកគុណដូច្នេះថា ព្រះថេរៈមាននាមប្បញ្ញត្តិដែលគ្រូទាំងឡាយដាក់ឱ្យថា **ពុទ្ធឃោសៈ** ជាបុគ្គលប្រដាប់ដោយសទ្ធា ចំណេះដឹង និងសេចក្ដីព្យាយាមដ៏ហ្មត់ចត់ក្រៃលែង ។ ជាបុគ្គលដែលគុណសមុទ័យ មានសីល អាចារៈ ភាពស្មោះត្រង់ និងភាពទន់ភ្លន់ជាដើម តាំងឡើងហើយ ។ ជាបុគ្គលមានសមត្ថភាពក្នុងការសិក្សារៀនសូត្រ ក្នុងលទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ ប្រកបដោយបញ្ញាឈ្លាសវៃ មានអំណាចក្នុងញាណ ដែលអ្វីៗមិនអាចកម្ចាត់បាន ក្នុងព្រះសាសនារបស់ព្រះបរមសាស្ដា ព្រម-

ដោយអដ្ឋកថា ដោយឡែកអំពីការសិក្សាព្រះត្រៃបិដក ។ ជាបុគ្គលដ៏ធំមួយអង្គក្នុងការចេះដឹងនូវវេយ្យាករណ៍ ប្រកបដោយសេចក្តីសុខដែលកម្មសម្បត្តិឱ្យកើតឡើងហើយ ទាំងពាក្យសម្តីច្បាស់លាស់ ពីរោះរណ្តំ ផ្អែមល្ហែម ជាពាក្យដែលគួរពោលប្រាសចាកទោស ជាមហាកវីដ៏ប្រសើរ ពេញលេញដោយចំណេះដឹងប្រាកដប្រជា ជាគ្រឿងប្រដាប់វង្សនៃព្រះថេរៈទាំងឡាយ មានប្រក្រតីនៅក្នុងមហាវិហារ តវង្សថេរវាទ មានញាណតាំងមាំល្អហើយ ក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ ជាដើម ជាប្រភេទដែលមានបដិសម្ភិទាជាបរិវារ បានរចនាហើយ (នូវអដ្ឋកថានេះ) ។

សូមឱ្យពុទ្ធបរិស័ទ មានទាន សីល ភាវនា ជាឧបនិស្ស័យបានគ្រប់គ្រាន់ក្នុងការសម្រេចមគ្គផល និង កុំគប្បីមានសេចក្តីអន្តរាយ ឬគ្រឿងរារាំងអ្វីណាមួយឡើយ ។

**ភ្នំពេញ ១៥ កើត ខែផល្គុន ព.ស.២៥៥៧**

**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**

# មាតិកា

**ឈ្មោះអត្ថបទ** **ទំព័រ**

I- ព្រះសុត្តន្តបិដកខ្មែរលេខ ១៨

- ពាក្យគួរយល់ដឹង ................................ ១
១- បាដិកសូត្រ ......................................២
២- ឧទុម្ពរិកសូត្រ .................................. ៦
៣- ចក្កវត្តិសូត្រ .................................. ១០
៤- អគ្គញ្ញសូត្រ ................................... ១៤
៥- សម្បសាទនីយសូត្រ ........................... ១៩
៦- បាសាទិកសូត្រ ................................. ២៦

II- ព្រះសុត្តន្តបិដកខ្មែរលេខ ១៩

- ពាក្យគួរយល់ដឹង ................................ ៣៤
១- លក្ខណសូត្រ .................................... ៣៥
២- សិង្គាលកសូត្រ ................................. ៥០
៣- អាដានាដិយសូត្រ ............................. ៥៦
៤- សង្គីតិសូត្រ .................................... ៦៤
៥- ទសុត្តរសូត្រ .................................... ៦៨

III- ទីឃនិកាយ ៣៤ សូត្រ


១- ព្រហ្មជាលសូត្រ
២- សាមញ្ញផលសូត្រ
៣- អម្ពដ្ឋសូត្រ
៤- សោណទណ្ឌសូត្រ
៥- កូដទន្តសូត្រ
៦- មហាលិសូត្រ
៧- ជាលិយសូត្រ
៨- មហាសីហនាទសូត្រ
៩- បោដ្ឋបាទសូត្រ
១០- សុភសូត្រ
១១- កេវដ្ដសូត្រ
១២- លោហិច្ចសូត្រ
១៣- តេវិជ្ជសូត្រ
១៤- មហាបទានសូត្រ
១៥- មហានិទានសូត្រ
១៦- មហាបរិនិព្វានសូត្រ
១៧- មហាសុទស្សនសូត្រ
១៨- ជនវសភសូត្រ
១៩- មហាគោវិន្ទសូត្រ
២០- មហាសមយសូត្រ
២១- សក្កបញ្ហសូត្រ
២២- មហាសតិប្បដ្ឋានសូត្រ
២៣- បាយាសិរាជញ្ញសូត្រ
២៤- បាដិកសូត្រ
២៥- ឧទុម្ពរិកសូត្រ
២៦- ចក្កវត្តិសូត្រ
២៧- អគ្គញ្ញសូត្រ
២៨- សម្បសាទនីយសូត្រ
២៩- បាសាទិកសូត្រ
៣០- លក្ខណសូត្រ
៣១- សិង្គាលកសូត្រ
៣២- អាដានាដិយសូត្រ
៣៣- សង្គីតិសូត្រ
៣៤- ទសុត្តរសូត្រ

# ព្រះសុត្តន្តបិដកខ្មែរលេខ ១៨

## ទីឃនិកាយ បាដិកវគ្គ មាន ៦ ព្រះសូត្រ គឺ

១- បាដិកសូត្រ ២- ឧទុម្ពរិកសូត្រ

៣- ចក្កវត្តិសូត្រ ៤- អគ្គញ្ញសូត្រ

៥- សម្បសាទនីយសូត្រ ៦- បាសាទិកសូត្រ ។

## ពាក្យគួរយល់ដឹង

≈≈≈≈≈≈≈≈≈≈≈≈≈≈

### ព្រះពុទ្ធវចនៈមាន ៥ និកាយ

ទីឃនិកាយមាន ៣៤ សូត្រ មជ្ឈិមនិកាយមាន ១៥២ សូត្រ សំយុត្តនិកាយមាន ៧៧៦២ សូត្រ អង្គុត្តរនិកាយមាន ៩៥៥៧ សូត្រ ចំណែកខុទ្ទកនិកាយ គឺ បាឋ: ១៥ និង វិនយបិដក ព្រមទាំង អភិធម្មបិដក ។

# ១. បាដិកសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅអនុប្បិយនិគម ក្នុងមល្លជនបទ ។ ក្នុងកាលនោះ បរិព្វាជកភគ្គវគោត្រ បានចូលក្នុងសំណាញ់ញាណនៃព្រះពុទ្ធអង្គ ទ្រង់បានយាងទៅកាន់អារាមរបស់បរិព្វាជកនោះឯង ។

ភគ្គវគោត្របរិព្វាជក បន្ទាប់ពីធ្វើបដិសណ្ឋារៈចំពោះព្រះដ៏មានព្រះភាគហើយ បានទូលព្រះអង្គអំពីរឿងសុនក្ខត្តលិច្ឆវិបុត្រធ្លាប់មកកាន់អារាមនេះ ហើយសុនក្ខត្តលិច្ឆវិបុត្របានពោលអំពីការលះបង់ព្រះដ៏មានព្រះភាគ មិនបាននៅពឹងផ្អែកនឹងព្រះដ៏មានព្រះភាគទៀតឡើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីដំណើររបស់សុនក្ខត្តលិច្ឆវិបុត្រ ពោលលាព្រះអង្គ ឈប់ពឹងផ្អែកជាមួយនឹងព្រះអង្គ ដោយអាងថា ព្រះអង្គមិនសម្តែងនូវឥទ្ធិបាដិហារ្យឱ្យដល់ខ្ញុំព្រះអង្គ ព្រះអង្គមិនបានបញ្ញត្តនូវច្បាប់ទម្លាប់ដល់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសុនក្ខត្តៈ កាលបើតថាគត ធ្វើឥទ្ធិបាដិហារ្យ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សក្តី

មិនធ្វើក្តី ... , កាលបើតថាគតបញ្ញត្តនូវច្បាប់ទម្លាប់ក្តី មិនបញ្ញត្តក្តី ធម៌ដែលតថាគតបានសម្តែងហើយ ដើម្បីប្រយោជន៍ឱ្យអស់ទៅនៃទុក្ខណា ធម៌នោះរមែងដឹកនាំបុគ្គលអ្នកប្រព្រឹត្តតាមធម៌ ឱ្យអស់ទៅនៃទុក្ខនោះ ដោយប្រពៃទេតើ ។

អដ្ឋកថាពន្យល់ថា កាលបើធម៌ដែលព្រះតថាគតត្រាស់សម្តែងនោះ ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ដល់អ្នកបដិបត្តិតាមធម៌នោះ ដូច្នេះ តើចាំបាច់ធ្វើឥទ្ធិបាដិហារ្យបានប្រយោជន៍អ្វីធ្វើក្តីមិនធ្វើក្តី មិននាំឱ្យសាបសូន្យពាក្យទូន្មានរបស់ព្រះអង្គឡើយ។ តាមពិត ព្រះតថាគត បំពេញព្រះបារមីមក ដើម្បីឱ្យមនុស្សនិងទេវតាទាំងឡាយ បានសម្រេចនូវព្រះនិព្វាន មិនមែនដើម្បីឱ្យធ្វើបាដិហារ្យនោះទេ ។ សុនក្ខត្តលិច្ឆវិបុត្រ ជាបុគ្គលពាលល្ងង់ខ្លៅរមិលគុណ ពោលតិះដៀលព្រះរតនត្រៃ លាចាកសិក្ខាបទ គេចចេញអំពីធម្មវិន័យនេះទៅ ដូចសត្វដែលទៅកើតក្នុងនរក ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីសុនក្ខត្តលិច្ឆវិ-បុត្រកាលពីនៅបួស ជាមួយនឹងអចេលកៈម្នាក់ដែលប្រព្រឹត្តដូចសុនខ ដើរវារជើង ៤ យកមាត់ត្របាក់ស៊ីនូវអាហារដែលគេចាក់ចោលលើផែនដី ។ ព្រោះហេតុតែ សុនក្ខត្តលិច្ឆវិបុត្រធ្លាប់ជាអចេលកៈមិច្ឆាទិដ្ឋិក្នុងជាតិមុន ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែង

ក្នុងនារទកស្សបជាតក ទើបធ្វើឱ្យលោកកើតសេចក្តីជ្រះថ្លាជាមួយនឹងអចេលកៈដែលប្រព្រឹត្តដូចសុនខនោះថា អើហ្ន៎ សមណៈនេះ ជាព្រះអរហន្តល្អពេកណាស់ ។ ក្រោយមក ៧ ថ្ងៃប៉ុណ្ណោះ អចេលកៈនោះ បានស្លាប់ទៅកើតជាអសុរកាយ ឈ្មោះកាលកញ្ជិកៈ ។

សុនក្ខត្តលិច្ឆវិបុត្រ បានសម្គាល់ខុសចំពោះអចេលកៈម្នាក់ទៀត ឈ្មោះកឡារមជ្ឈកៈ ថាជាព្រះអរហន្តផងដែរ ។ ក្រោយមក មិនជាយូរប៉ុន្មាន អចេលកៈឈ្មោះកឡារមជ្ឈកៈ បានត្រឡប់មកមានប្រពន្ធកូន អត់លាភ អត់យស ហើយស្លាប់ទៅ ។

បន្តមកទៀត ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីអចេលកៈឈ្មោះ បាដិកបុត្រ ដែលសុនក្ខត្តលិច្ឆវិបុត្រមានការគាំទ្រយ៉ាងមាំទាំ ។ អចេលកៈឈ្មោះបាដិកបុត្រនេះ ជាអ្នកពោលកុហកមានអំនួតអួតអាង បានប្រកាសធ្វើឥទ្ធិបាដិហារ្យឱ្យក្រៃលែងជាងព្រះដ៏មានព្រះភាគ ទីបំផុតត្រូវចាញ់ខ្លួនឯងយ៉ាងដំណំ ។ ក្នុងកាលនោះ ព្រះពុទ្ធអង្គទ្រង់បានសម្តែងព្រះធម៌ញុំាងបរិស័ទរាប់ម៉ឺននាក់ដែលសុនក្ខត្តលិច្ឆវិបុត្របបួលឱ្យមកមើលបាដិហារ្យ ឱ្យបានរួចពីចំណង ឆ្លងអន្លង់ធំ ។

ខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់

សម្ដែងអំពីការបញ្ញត្តនូវច្បាប់ទម្លាប់ក្នុងលោកផ្សេងៗ ឱ្យភគ្គវ-គោត្របរិព្វាជកបានស្ដាប់ សម្រេចនូវសេចក្ដីជ្រះថ្លាចំពោះព្រះដ៏-មានព្រះភាគ ហើយប្ដេជ្ញាថា ខ្ញុំព្រះអង្គនឹងប្រុងរក្សាចំពោះតែសេចក្ដីជ្រះថ្លានោះឯងឱ្យបានប្រពៃ ។ ភគ្គវគោត្របរិព្វាជក បានឧបនិស្ស័យនៃមគ្គផល ទៅក្នុងភពខាងមុខ ដោយសារបានស្ដាប់នូវព្រះសូត្រនេះអំពីព្រះដ៏មានព្រះភាគ ។

**សូមអនុមោទនា !**

# ព្រោះសក្កាយទិដ្ឋិ

ព្រោះសក្កាយទិដ្ឋិ ទើបនាំឱ្យមានរឿងខ្វល់នឹងខ្លួនឯងប្រកាន់ខុសផ្សេងៗ ដូចពួកអចេលកៈ និងសុនក្ខត្តលិច្ឆវិបុត្រជាដើម ។ កាលដែលបានកំណត់ដឹងនូវបញ្ចក្ខន្ធ ចូលកាន់ភូមិព្រះអរិយៈ ឈ្មោះថា ចូលកាន់ភូមិដ៏ស្ងប់រំងាប់ រៀបរយ ។

## ២. ឧទុម្ពរិកសូត្រ

ព្រះពុទ្ធអង្គទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះ និគ្រោធបរិព្វាជក អាស្រ័យនៅក្នុងបរិព្វាជការាម ជារបស់ព្រះនាងទេវីឧទុម្ពរិកា មួយអន្លើដោយបរិព្វាជកបរិស័ទ ជាច្រើន ប្រមាណ ៣០០០ នាក់ និយាយសើចហៅ ប្រកបដោយ តិរច្ឆានកថា ។ សន្ធានគហបតី ជាព្រះអនាគាមី បានអញ្ជើញមក ជួបនឹងនិគ្រោធបរិព្វាជក ហើយបានពោលសរសើរព្រះដ៏មាន-ព្រះភាគថា ទ្រង់សេពនូវសេនាសនៈដ៏ស្ងាត់ តាំងនៅក្នុងព្រៃ-ស្រោង មានសំឡេងតិច ប្រាសចាកពាក្យសម្ដីរបស់អ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស និង គួរដល់ការលាក់ខ្លួន ពួនអាត្មាបាន ។ និគ្រោធបរិព្វាជកបានរិះគន់ព្រះដ៏មានព្រះភាគ ថា ព្រះអង្គចូលចិត្តនៅទីស្ងាត់ៗ ព្រោះមិនហ៊ានចេញមកចរចា ល្បងប្រាជ្ញាជាមួយនឹងអ្នកណាៗនោះឯង បើព្រះសមណគោតម គប្បីមករកបរិស័ទនេះ ពួកយើងគួរសាកសួរលោកមួយប្រស្នា ល្បងមើលដែរ ពួកយើងត្រូវចាប់បង្វិលព្រះសមណគោតមនោះ ឱ្យដូចជាគេចាប់បង្វិលឆ្នាំងទទេមិនខាន ។ សន្ធានគហបតី នឹក

អាណិតនិគ្រោធបរិព្វាជក គិតថា បើព្រះដ៏មានព្រះភាគស្តេចយាងមក នឹងបានដាក់ចុះនូវមានះដូចជាទង់ដែលបរិព្វាជកនេះបានលើកឡើង ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបពាក្យឆ្លើយឆ្លងរបស់សន្ធាន-គហបតី ជាមួយនឹងនិគ្រោធបរិព្វាជកដោយទិព្វសោត ហើយទ្រង់ក៏បានយាងចុះពីលើភ្នំគិជ្ឈកូដមកក្នុងគ្រានោះឯង ។ កិច្ចសន្ទនាក៏បានចាប់ផ្តើមក្នុងប្រធានបទគឺ «ការខ្ពើមបាបដោយតបៈ» តើការខ្ពើមបាបដោយតបៈ ដូចម្តេចឈ្មោះថា បរិបូណ៌ ដូចម្តេចឈ្មោះថា មិនបរិបូណ៌ ។

ព្រះពុទ្ធអង្គ ទ្រង់ត្រាស់អំពីឧបក្កិលេសនៃអ្នកប្រព្រឹត្តតបៈ ជាបន្តទ្រង់ត្រាស់អំពីក្រមរ សំបក ស្រាយ ខ្លឹមនៃអ្នកប្រព្រឹត្តតបៈនោះ ប៉ុន្តែអ្វីដែលប្រសើរវិសេសជាងការប្រព្រឹត្តនូវតបៈនោះៗទៅទៀត គឺព្រហ្មចរិយធម៌សម្រេចមគ្គផល តាមការទូន្មាននៃព្រះតថាគត ។

ទោះជានិគ្រោធបរិព្វាជក បានសូមខមាទោសចំពោះព្រះដ៏មានព្រះភាគក៏ដោយ ប៉ុន្តែប្រព្រឹត្តទៅដោយមាយាលាក់ពុតជាបុគ្គលមានអំនួតអួតអាង មិនអាចទទួលយកការណែនាំអំពីព្រះដ៏មានព្រះភាគបានឡើយ ទើបព្រះអង្គទ្រង់ត្រាស់ថា បុគ្គល

អ្នកចេះដឹង ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រៀនប្រដៅ ... ។

ព្រោះហេតុតែនិគ្រោធបរិព្វាជក និងពួកបរិស័ទទាំងបីពាន់នាក់នោះ មិនទាន់មានឧបនិស្ស័យសម្រេចមគ្គផល ទើបព្រះដ៏-មានព្រះភាគ ព្រះអង្គមិនបានហាមឃាត់មារ ដែលមកចូលជ្រែកពួកបរិព្វាជកទាំងអស់នោះឡើយ ហើយព្រះអង្គទ្រង់ហោះត្រឡប់ទៅលើភ្នំគិជ្ឈកូដវិញ ឯសន្ធានគហបតី ក៏បានចូលទៅកាន់ក្រុងរាជគ្រឹះ ក្នុងពេលនោះដែរ ។

អដ្ឋកថាប្រាប់ថា ពួកបរិព្វាជកទាំងនោះ មិនបានសម្រេចគុណវិសេស ព្រោះស្ដាប់នូវព្រះសូត្រនេះក៏ពិត ប៉ុន្តែបានជាឧបនិស្ស័យនៃភ័ព្វវាសនា តទៅខាងមុខ ។

**សូមអនុមោទនា !**

## ឧបក្កិលេសនៃអ្នកប្រព្រឹត្តតបះ

ព្រោះតែមិនបានទទួលនូវពុទ្ធោវាទ សិក្សាកំណត់ដឹងនូវឧបាទានក្ខន្ធ ទើបមិនមាននូវមគ្គព្រហ្មចរិយធម៌ ។ ព្រោះមិនមាន

នូវមគ្គព្រហ្មចរិយធម៌ ទើបមិនអាចគាស់រំលើងនូវឫសគល់នៃឧបក្កិលេសបាន ទោះជាប្រព្រឹត្តតបះតាមបែបផ្សេងៗ ឬបានអ្វីៗនៅក្នុងលោកនេះ យ៉ាងណាក៏ដោយ ។

លោកនៃការរស់នៅ គឺគ្រាន់តែជាអារម្មណ៍របស់ចិត្តតែប៉ុណ្ណោះ ដោយបរមត្ថ គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ ។ ដូច្នេះ អ្វីដែលជាការរស់នៅក្នុងលោក គឺចិត្តដឹងអារម្មណ៍នោះៗហ្នឹងឯង ព្រោះបានអប់រំចិត្តានុបស្សនាសតិប្បដ្ឋាន ទើបបានមិនប្រកាន់ចិត្តដឹងអារម្មណ៍ថាជាតួខ្លួនឡើយ ។ កាលបើឃើញត្រឹមតែចិត្តដឹងអារម្មណ៍ប៉ុណ្ណោះ តើមាននោះជារបស់អញមកពីណា ។

# ៣. ចក្កវត្តិសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាដងព្រៃ ជិតមាតុលានគរក្នុងដែនមគធៈ ។ ពួកមនុស្សរាប់ម៉ឺននាក់ បានចូលក្នុងសំណាញ់-ញាណនៃព្រះពុទ្ធអង្គ ព្រមដោយភិក្ខុសង្ឃ ។ ពួកមនុស្សក្នុងមាតុលានគរ បានថ្វាយចង្ហាន់ដល់ព្រះសង្ឃពីរម៉ឺនអង្គ ដែលមានព្រះសម្មាសម្ពុទ្ធជាព្រះប្រធាន។ ភត្តកិច្ចរួចហើយ ទើបព្រះបរម-សាស្តាទ្រង់ត្រាស់សម្តែងប្រាប់ឱ្យភិក្ខុទាំងឡាយ មានខ្លួនជាទីពឹងមានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។

ក្នុងពាក្យថា មានខ្លួនជាទីពឹងពំនាក់នេះ គឺសំដៅយកលោកិយធម៌ និងលោកុត្តរធម៌ឈ្មោះថាខ្លួន ព្រោះហេតុដូច្នេះទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ជាបន្តថា ចូរមានធម៌ជាទីពឹងមានធម៌ជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។

ពាក្យថា កុំយករបស់ដទៃជាទីពឹងពំនាក់ គឺជាពាក្យបដិសេធទីពឹងយ៉ាងដទៃ ។ ដោយពិត អ្នកដទៃរមែងជាទីពឹងនៃអ្នកដទៃ មិនបានឡើយ ព្រោះអ្នកដទៃនឹងបរិសុទ្ធដោយសេចក្តីព្យាយាមរបស់អ្នកដទៃផ្សេងទៀត មិនបានហ្នឹងឯង ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់សម្ដែងសតិប្បដ្ឋាន ៤ មក បញ្ជាក់ត្រង់ពាក្យដែលថាមានខ្លួនជាទីពឹង គឺមានសតិប្បដ្ឋាន ៤ នេះឯងដែលជាទីពឹង ។ ព្រះអង្គទ្រង់ត្រាស់សតិប្បដ្ឋាន ៤ នេះថា ជាទីគោចររបស់បិតា កាលបើអ្នកទាំងឡាយប្រព្រឹត្តក្នុងទីគោចរ ជាវិស័យដែលមានមកអំពីបិតារបស់ខ្លួនដូច្នេះ មារក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ឡើយ ។

ជាបន្តក្នុងព្រះសូត្រនេះ ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា **កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ** ។ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះ រមែងចម្រើនឡើង ព្រោះហេតុមកអំពីបានសមាទាននូវកុសលធម៌ទាំងឡាយ យ៉ាងនេះឯង ។

បទថា **កុសលានំ** គឺធម៌ដែលមិនមានទោសជាលក្ខណៈ ។

បទថា **សមាទានហេតុ** គឺ ព្រោះហេតុសមាទានហើយប្រព្រឹត្ត ។

បទថា **ឯវមិទំ បុញ្ញំ បវឌ្ឍតិ** ដោយសេចក្ដីថា ផលបុណ្យដែលជាលោកិយនិងលោកុត្តរនេះ រមែងចម្រើនយ៉ាងនេះឯង ។ ម្យ៉ាងទៀត ពាក្យថា ផលបុណ្យ គប្បីជ្រាបថា បានដល់ទាំងបុណ្យ ទាំងផលរបស់បុណ្យថ្នាក់ខ្ពស់ៗ ។

នៅក្នុងព្រះសូត្រនេះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ផលបុណ្យជាលោកិយ ដោយសិរីសម្បត្តិរបស់ស្តេចចក្រពត្តិ ដល់ខាងចុងនៃព្រះសូត្រ ព្រះបរមសាស្តា ទ្រង់ត្រាស់វិបាកនៃលោកុត្តរកុសល ។

ត្រង់បទថា **ឯវមិទំ បុញ្ញំ** ដោយសេចក្តីថា សូម្បីបុណ្យដែលជាលោកុត្តរនេះ រមែងចម្រើនរហូតដល់អស់អាសវៈ ។ ព្រះដ៏មានព្រះភាគ ត្រាស់ព្រះធម៌ទេសនាបញ្ចប់ដោយព្រះអរហត្តជាទីបំផុត ។

ក្នុងពេលចប់ព្រះសូត្រ ព្រះភិក្ខុពីរម៉ឺនអង្គសម្រេចព្រះ-អរហត្ត ចំណែកពុទ្ធបរិស័ទជាងប្រាំបីម៉ឺននាក់ បានក្រេបផឹកនូវទឹកអម្រឹត ក្នុងគ្រានោះឯង ។

**សូមអនុមោទនា !**

## ធម៌ជាទីពឹង

ក្រៅអំពីការចម្រើនឡើងនូវកុសលធម៌ កំណត់ដឹងឧបា-ទានក្ខន្ធ តើមានអ្វីក្នុងលោកនេះដែលនាំឱ្យអស់ខ្វល់ ដូចជា រូបស្អាត សំឡេងពីរោះ ប្រទេសជឿនលឿន កាមគុណជាទិព្វ ។ល។

ដោយពិត អ្វីដែលនាំឱ្យមានទុក្ខកង្វល់ មិនចេះអស់ មិនចេះហើយ គឺកិលេសក្នុងចិត្តខ្លួនឯង ដូច្នេះទើបត្រូវស្វែងរកសេចក្ដីស្ងប់ដោយការប្រព្រឹត្តធម៌តែប៉ុណ្ណោះ ។

មនុស្សយើង តែងតែអន្ទះអន្ទែង ក្រវល់ក្រវាយក្នុងរបស់ដែលខ្លួនឯងហួងហែង មិនបានសិក្សាកំណត់ដឹងការពិតឡើយ ។ អ្វីជាការពិត ? គឺអ្វីណាដែលកើតឡើង អ្វីនោះឯងជាការពិត ព្រោះមានបច្ច័យត្រឹមត្រូវ ។ បើសិក្សាកំណត់ដឹងការពិតបានហើយ ក៏រមែងលះបង់នូវចំណង់ក្នុងរបស់ដែលអត់ ដែលមិនមាន មិនអន្ទះអន្ទែង ក្រវល់ក្រវាយ ទៅតាមចំណង់នោះឡើយ ព្រមសុខចិត្តជាមួយនឹងអ្វីដែលកើត ដែលមាន កំពុងប្រាកដ ហើយក៏ចាក់ធ្លុះ យល់ដឹងច្បាស់ថា អ្វីជាការពិត ។

## ៤. អគ្គញ្ញសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះ វាសេដ្ឋសាមណេរ និងភារទ្វាជសាមណេរ មានប្រាថ្នានឹងបួសជាភិក្ខុ ទើបធ្វើ តិត្ថិយបរិវាស ក្នុងសម្នាក់នៃភិក្ខុទាំងឡាយ ។

អដ្ឋកថាថា សាមណេរទាំងពីរអង្គនេះ កើតក្នុងត្រកូល ព្រាហ្មណមហាសាល មានទ្រព្យ ៨០ កោដិដូចគ្នា ជាអ្នកបានរៀន ចេះចប់គម្ពីរត្រៃវេទ ។ ព្រោះស្តាប់ **វាសេដ្ឋសូត្រ** ក្នុងមជ្ឈិម-និកាយ ក៏បានដល់ព្រះត្រៃសរណគមន៍ លុះស្តាប់ **តេវិជ្ជសូត្រ** ក្នុង ទីឃនិកាយហើយ ក៏បួសជាសាមណេរ ដល់ពេលនេះ មានប្រាថ្នា នឹងបួសជាភិក្ខុទៀត ទើបនៅតិត្ថិយបរិវាស ។

នៅវេលាថ្ងៃរសៀល ព្រះដ៏មានព្រះភាគទ្រង់ចង្ក្រមក្នុងទី វាល ត្រង់ម្លប់ប្រាសាទ ។ សាមណេរទាំងពីរអង្គនេះ បាននាំគ្នា ដើរចង្ក្រមតាមព្រះដ៏មានព្រះភាគ ដោយគិតថា ក្រែងបានស្តាប់ ព្រះធម៌អំពីព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សន្ទនា ជាមួយនឹងសាមណេរទាំងពីរអង្គដោយព្រះហឫទ័យអនុគ្រោះ ។

បទសន្ទនា តាំងនៅក្នុងប្រធានបទគឺវណ្ណៈទាំង ៤ ផ្ដើមដោយការប្រកាន់វណ្ណៈរបស់ពួកព្រាហ្មណ៍ ថាវណ្ណៈព្រាហ្មណ៍ប្រសើរបំផុត ហើយជេរប្រទេចសាមណេរទាំងពីរអង្គថា ចោលវណ្ណៈដ៏ប្រសើរ ត្រឡប់ទៅកាន់វណ្ណៈថោកថយ គឺចូលកាន់សម្នាក់សមណៈត្រងោល ជាវណ្ណៈខ្មៅវិញ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងអំពីការងារ តាមផ្លូវកាយ ផ្លូវវាចា និងមនោកម្ម ដែលបែងចែកមនុស្សឱ្យប្រសើរ ឬឱ្យមិនប្រសើរ ។ ក្នុងវណ្ណៈទាំង ៤ វណ្ណៈណាក៏អាចប្រព្រឹត្តព្រហ្មចរិយ-ធម៌បាន កាលបើប្រព្រឹត្តធម៌ដាក់ចុះនូវភារៈ អស់អាសវៈ សម្រេចប្រយោជន៍របស់ខ្លួនតាមលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ បុគ្គលក្នុងវណ្ណៈនោះ ប្រាកដជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំងនោះដោយធម៌ពិត មិនមែនដោយអធម៌ទេ ។ ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ននិងបរលោក ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងពីរោះ គួរជាទីរីករាយជ្រះថ្លាណាស់ គឺព្រះអង្គត្រាស់សម្ដែងថា ម្នាលវាសេដ្ឋៈ អ្នកទាំងឡាយមានជាតិផ្សេងៗគ្នា មានឈ្មោះផ្សេងៗគ្នា មានគោត្រ

ផ្សេងៗគ្នា មានត្រកូលផ្សេងៗគ្នា ចេញចាកផ្ទះមកកាន់ផ្នួស បើមានគេសួរថា លោកទាំងឡាយជាអ្វីដូច្នេះ ចូរប្រាប់ទៅគេវិញថា យើងជាសមណសក្យបុត្តិយ៍ ។ ម្នាលវាសេដ្ឋៈ បើជនណាមានសទ្ធា គឺការជឿស្លុងចុះស៊ប់ហើយ មានឫសដុះតាំងខ្ជាប់មាំមួនក្នុងតថាគត ទោះបីសមណព្រាហ្មណ៍ ទេវតា ព្រហ្ម ឬនរណាមួយក្នុងលោក ក៏មិនអាចនឹងបំបែរឱ្យត្រឡប់បានឡើយ ជននោះគួរនិយាយយ៉ាងនេះថា ខ្ញុំជាបុត្រ ជាឱរសនៃព្រះដ៏មានព្រះភាគ កើតមកអំពីព្រះឱស្ឋរបស់ព្រះអង្គ កើតមកពីធម៌ ធម៌តាក់តែងមកជាធម្មទាយាទ ។ ព្រោះហេតុអ្វីបានជាតថាគតសម្ដែងដូច្នេះ ម្នាលវាសេដ្ឋៈ ព្រោះពាក្យថា ធម្មកាយ ដូច្នេះក្ដី ព្រហ្មកាយ ដូច្នេះក្ដី ធម្មភូត ដូច្នេះក្ដី ព្រហ្មភូត ដូច្នេះក្ដី គឺជាឈ្មោះរបស់តថាគត ។

ជាបន្តក្នុងព្រះសូត្រ ព្រះបរមសាស្ដាទ្រង់ត្រាស់អគ្គញ្ញ-សូត្រ គឺព្រះអង្គទ្រង់លើកអំពីការចម្រើនឡើងនៃលោកផែនដី អាភស្សរព្រហ្មច្យុតមកកើតជាមនុស្ស ... ។ **ឥតិ ខោ វាសេដ្ឋា ឯតស្ស ខត្តិយមណ្ឌលស្ស បោរាណេន អគ្គញ្ញេន អក្ខរេន អភិនិព្វត្តិ អហោសិ** ។ ម្នាលវាសេដ្ឋៈ ហេតុដូច្នោះ អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់ខត្តិយមណ្ឌលនោះយ៉ាងនេះឯង ។

បទថា **អគ្គញ្ញេន** ដោយសេចក្តីថា ការកើតឡើងនៃអក្សរ ដែលកើតឡើងក្នុងសម័យនៃលោកកើតឡើង ដែលបានដឹងគ្នាទៅវិញទៅមកថា លើស ឬក្នុងចំណែកដ៏លើស ។

**អក្ខរះ** គឺជាពាក្យសម្រាប់កំណត់ឈ្មោះ បញ្ញត្តហៅ ដូចជាហៅថា **ខត្តិយោ** ជាដើម ។ មិនមែនចំពោះតែអក្ខរៈប៉ុណ្ណោះទេ ពួកមនុស្សទាំងនោះ បានធ្វើការអភិសេកបុគ្គលនោះ ដោយការលើកតម្កើងដល់ទៅ ៣ ដងថា សូមឱ្យព្រះអង្គជាធំក្នុងស្រែរបស់ពួកយើង ដូច្នេះឯង ។ ព្រះមហាសម្មតិជាក្សត្រក្នុងកាលនោះ គឺជាព្រះបរមពោធិសត្វនៃពួកយើង ។

ពាក្យហៅវណ្ណៈទាំង ៤ គ្រាន់តែអក្ខរៈដែលមនុស្សក្នុងកាលនោះ សន្មតទៅតាមការងារប៉ុណ្ណោះ ចំពោះអ្វីដែលបែងចែកសត្វឱ្យប្រសើរ ឬឱ្យថោកទាប គឺនៅលើកម្ម បានដល់កុសលកម្ម ឬអកុសលកម្មហ្នឹងឯង ។ នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា

ខត្តិយៈជាជាតិប្រសើរបំផុតក្នុងប្រជុំជន ដែលជាអ្នករលឹកដល់គោត្រ ចំណែកបុគ្គលដែលបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺប្រសើរបំផុតក្នុងពួកទេវតានិងមនុស្សទាំងឡាយ ។

សាមណេរទាំងពីរអង្គនោះ កំពុងបង្អោនចិត្តដោយស្មារតី

នឹករលឹកដល់សេចក្តីនៃព្រះសូត្រនេះឯង ក៏បានសម្រេចព្រះ-អរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ។

**សូមអនុមោទនា !**

## មនុស្សសាងការងារ ការងារសាងមនុស្ស

បើប្រៀបទៅនឹងសាសនាអាទិទេព មនុស្សយើងហ្នឹងឯង ដែលជាព្រះមួយអង្គ សម្រាប់សាងខ្លួនឯង ពីព្រោះមនុស្សត្រូវធ្វើការងារ ។ ការងារល្អសាងមនុស្សឱ្យល្អ ការងារអាក្រក់ សាងមនុស្សឱ្យអាក្រក់ ការងារសាងបរលោករៀង១ខ្លួន ជាពិសេសណាស់នោះ គឺការងារសម្អាតចិត្តរបស់ខ្លួនឱ្យផ្លូវផង់ ចូលកាន់ភូមិព្រះអរិយៈ ។

# ៥. សម្បសាទនីយសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅបាវារិកម្ពវ័ន ក្នុងស្រុកនាឡន្ទា ជិតដល់វេលាចូលវស្សាទី ៤៥ នៃព្រះអង្គ ។ ក្នុងពេលនោះ ព្រះសារីបុត្ត បានក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគយ៉ាងនេះថា សមណៈឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលប់ជាងព្រះដ៏មានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខ ក៏មិនមាន ក្នុងកាលឥឡូវនេះ ក៏មិនមាន ។

ព្រះសារីបុត្ត មិនមានចេតោបរិយញ្ញាណ ជ្រាបទៅក្នុងព្រះគុណនៃព្រះសម្មាសម្ពុទ្ធទាំងឡាយដោយសព្វគ្រប់ឡើយ ប៉ុន្តែព្រះសារីបុត្តអាស្រ័យសាវកបារមីញាណ ទូលព្រះដ៏មានព្រះភាគថា **អបិច មេ ភន្តេ ធម្មន្វយោ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានដឹងដោយអនុមានញ្ញាណនៃធម៌ គឺការកាន់យកតាមន័យនៃសាវកបារមីញាណហ្នឹងឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូច នគរចុងដែនរបស់

ព្រះរាជា មានជើងបន្ទាយមាំ មានសសរខ្លោងទ្វារកំពែងមាំ មានច្រកទ្វារតែមួយ អ្នករក្សាទ្វារនៃនគរនោះ ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ហាមប្រាមនូវពួកមនុស្សដែលខ្លួនមិនធ្លាប់ស្គាល់ បើកឱ្យតែពួកមនុស្សដែលខ្លួនធ្លាប់ស្គាល់ឱ្យចូលទៅ ។ អ្នករក្សាទ្វារនោះ កាលដើរត្រួតត្រាមើលផ្លូវកំពែងខ្វាត់ខ្វែងដោយជុំវិញនៃនគរនោះ ក៏មិនបានឃើញនូវទី ត នៃកំពែង ឬចន្លោះនៃកំពែងឡើយ ដោយហោចទៅ សូម្បីគ្រាន់តែឆ្មាចេញរួចក៏ពុំមានដែរ ។ អ្នករក្សាទ្វារនោះមានគំនិតយ៉ាងនេះថា ពួកសត្វដែលធំៗណាមួយចូលមកកាន់នគរនេះក្តី ចេញទៅវិញក្តី សត្វទាំងអស់នោះ រមែងចូលមកឬចេញទៅ តាមទ្វារនេះប៉ុណ្ណោះ សេចក្តីនេះ យ៉ាង-ណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានដឹងតាមទំនងធម៌ (អដ្ឋកថាថា អនុមានញ្ញាណនៃធម៌) យ៉ាងនោះដែរ ។

ព្រះសារីបុត្តបានសម្តែងបច្ចន្តនគរ ១ , កំពែង ១ , ផ្លូវដើរជុំវិញកំពែង ១ , ទ្វារ ១ , មនុស្សយាមទ្វារដ៏ឆ្លាត ១ , សត្វធំដែលចូលចេញតាមទ្វារ ១ និងសម្តែងការប្រាកដនៃសត្វទាំងនោះដល់អ្នកយាមទ្វារនោះ ១ ។ ចំពោះឧបមានេះ គប្បីជ្រាបដូចតទៅ :

១- ព្រះនិព្វានដូចព្រះនគរដ៏សុខសាន្ត

២- សីលដូចកំពែងដ៏រឹងមាំ

៣- ហិរិដូចផ្លូវដើរព័ទ្ធជុំវិញកំពែង

៤- អរិយមគ្គដូចទ្វារនៃព្រះនគរ

៥- ព្រះធម្មសេនាបតីដូចអ្នកយាមទ្វារដ៏ឆ្លាត

៦- ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដែលត្រាស់ដឹងគ្រប់កាលទាំងបី ដូចសត្វធំៗដែលចូលចេញតាមទ្វារ ។

៧- ការប្រាកដដោយសីលនិងសមថៈជាដើមរបស់ព្រះ-សម្មាសម្ពុទ្ធទាំងឡាយនោះ ដល់ព្រះធម្មសេនាបតី ដូចការប្រាកដនៃសត្វធំៗដល់អ្នកយាមទ្វារដ៏ឆ្លាត ។

ព្រះធម្មសេនាបតីសារីបុត្ត ធ្លាប់ចូលទៅរកអ្នកបួសដទៃក្រៅព្រះពុទ្ធសាសនា អស់ ៩៥ នាក់ហើយ រហូតទាល់តែបានចូលគាល់ព្រះដ៏មានព្រះភាគនៅគុហាសូករខាតា ដើម្បីស្តាប់ព្រះធម៌ ទើបបាននូវសាវកបារមីញាណ ឥឡូវនេះ បានប្រកាសគុណរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយដោយអនុមានញ្ញាណ អាស្រ័យសាវក-បារមីញាណនោះឯង ដូចមានក្នុងព្រះសូត្រស្រាប់ ពោលគឺ

- ទ្រង់លះនូវនីវរណធម៌ទាំង ៥ មានព្រះហឫទ័យតាំងខ្ជាប់ល្អក្នុងសតិប្បដ្ឋានទាំង ៤ ចម្រើននូវពោជ្ឈង្គ ៧ តាមគួរដល់សេចក្តីពិត បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។

- ទ្រង់សម្តែងធម៌ ក្នុងកុសលធម៌ទាំងឡាយគឺពោធិ-បក្ខិយធម៌ ៣៧ ប្រការ ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ញុំាំងបុគ្គលឱ្យស្គាល់នូវអាយតនៈទាំងឡាយក្នុង ៦ ក្រៅ ៦ ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងដំណើរចុះកាន់គភ៌ទាំងឡាយមាន ៤ យ៉ាង ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងអាទេសនវិធី គឺវិធីសម្រាប់ទាយមាន ៤ យ៉ាង ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងទស្សនសមាបត្តិទាំងឡាយ ៤ យ៉ាង ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងបុគ្គលប្បញ្ញត្តិទាំងឡាយ ៧ ពួក ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងបធានធម៌ គឺពោជ្ឈង្គទាំង ៧ ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងបដិបទាទាំងឡាយ ៤ យ៉ាង ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្តែងធម៌ ក្នុងភស្សសមាចារ គឺកិរិយាប្រព្រឹត្តល្អដោយវាចា បានដល់ការមិននិយាយសម្តីប្រកបដោយមុសាវាទផង

មិននិយាយពាក្យញុះញង់ ដែលធ្វើឱ្យគេបែកបាក់គ្នាផង មិននិយាយនូវពាក្យដែលកើតពីការប្រណាំងប្រជែងផង ជាអ្នកមិនប្រាថ្នាចង់ឈ្នះ ពិចារណាដោយបញ្ញាទើបពោលផង និយាយនូវសម្ដីគួរឱ្យអ្នកផងយកទុកក្នុងហឫទ័យ តាមកាលគួរផង នេះជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងបុរិសសីលសមាចារ គឺថា ជាអ្នកមានសច្ចធម៌ផង មានសទ្ធាផង មិនកុហកផង មិននិយាយរួសរាយហួសហេតុផង មិននិយាយបញ្ឆិតបញ្ឆៀងផង មិននិយាយគំរាមគេផង មិននាំទៅនូវលាភដើម្បីលាភផង ជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រព្រឹត្តស្មើ ប្រកបរឿយៗនូវសេចក្ដីព្យាយាមជាគ្រឿងភ្ញាក់រលឹក មិនខ្ជិលច្រអូស ប្រារព្ធសេចក្ដីព្យាយាម មានឈាន មានសតិ មានបដិភាណដ៏ល្អ មានគតិ គឺប្រាជ្ញាជាគ្រឿងស្ទុះទៅ មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ មានគំនិតជាអ្នកមិនជាប់ជំពាក់ក្នុងកាមទាំង-ឡាយផង មានសតិផង មានប្រាជ្ញាខ្ជាប់ខ្ជួនផង នេះជាព្រះធម៌-ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងអនុសាសនវិធាទាំងឡាយ ៤ យ៉ាង ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងវិមុត្តិញ្ញាណនៃបុគ្គលដទៃ ជាព្រះ-ធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងសស្សតវាទទាំងឡាយ ៣ យ៉ាង ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ជាព្រះធម៌ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងចុតូបបាតញ្ញាណ ជាព្រះធម៌-ទេសនាដ៏ប្រសើរក្រៃលែង ។

- ទ្រង់សម្ដែងធម៌ ក្នុងឥទ្ធិវិធា ២ យ៉ាង ជាព្រះធម៌-ទេសនាដ៏ប្រសើរក្រៃលែង ។

ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយក្ដី ដែលនឹងមានក្នុងកាលជាអនាគតក្ដី គឺមានព្រះញាណស្មើៗនឹងព្រះ-តថាគត ព្រះពុទ្ធបរមគ្រូនៃយើង ក្នុងការត្រាស់ដឹងហ្នឹងឯង ។ នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត អ្នកចូរពោលនូវធម្មបរិយាយនេះ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ឱ្យរឿយៗចុះ ។

**សូមអនុមោទនា !**

# បទុមរតនៈ

ព្រះសម្មាសម្ពុទ្ធ ប្រៀបដូចជាផ្កាឈូករីក

ព្រះធម៌ ប្រៀបដូចជាកេសរនៃផ្កាឈូក

ពុទ្ធបរិស័ទ ប្រៀបដូចជាមេឃ្មុំហើរទៅនាំយកកេសរផ្កាឈូក មកធ្វើក្បាលទឹក ។ ក្បាលទឹកឃ្មុំជាឈ្មោះនៃការសម្រេចមគ្គផល ។

តថាគតគប្បីកើតជាទេវតា ឬកើតជាគន្ធព្វត្រាច់ទៅតាមអាកាស ព្រោះអាសវៈណាក្តី គប្បីដល់នូវភាពនៃខ្លួនជាយក្ស និងជួបប្រទះនូវភាពនៃខ្លួនជាមនុស្ស ព្រោះអាសវៈណាក្តី អាសវៈទាំងអស់នោះ របស់តថាគត អស់ហើយ បានកម្ចាត់បង់ហើយ ធ្វើឱ្យរបួតចំណងហើយ ។ ផ្កាឈូកស ដុះឡើងផុតពីទឹក មិនជាប់ដោយទឹកយ៉ាងណា តថាគតមិនជាប់ដោយលោក យ៉ាងនោះឯង ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ តថាគតជាព្រះពុទ្ធ ។

# ៦. បាសាទិកសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ នាអម្ពវ័ន របស់ពួកសក្យៈ ដែលមានឈ្មោះថា វេធញ្ញៈ ប្រែថា អ្នកហាត់បាញ់ធ្នូ ។ សម័យនោះឯង និគ្គណ្ឋនាដបុត្ត ទើបតែធ្វើមរណកាលថ្មីៗក្នុងនគរបាវា ។ ព្រោះតែការប្រកាសលទ្ធិដែលមិនមែនជានិយ្យានិកធម៌ មិនប្រព្រឹត្តទៅដើម្បីស្ងប់រំងាប់ បានធ្វើឱ្យពួកនិគ្រន្ថដែលជាសិស្សបែកបាក់គ្នា ចាក់ដោតគ្នាដោយលំពែងគឺមាត់ ។

ព្រះចុន្ទៈ ជាប្អូនព្រះសារីបុត្ត នៅចាំវស្សាក្នុងក្រុងបាវា បានចូលទៅរកព្រះអានន្ទដ៏មានអាយុដែលជាព្រះឧបជ្ឈាយ៍ ថ្វាយបង្គំក្រាបទូលរឿងរ៉ាវនោះ ។ ព្រះអានន្ទត្ថេរ បាននាំព្រះចុន្ទៈចូលគាល់ព្រះបរមសាស្តា ហើយក៏បានក្រាបបង្គំទូលព្រះដ៏មាន-ព្រះភាគនូវពាក្យដែលមានមូលហេតុ គួរនឹងក្រាបបង្គំទូល ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីសាស្តាក្នុងលោក និងការប្រកាសធម៌ ព្រមទាំងសាវ័ករបស់សាស្តានោះ ។ ទំព័រ ២៥៤ ព្រះអង្គត្រាស់ថា ម្នាលចុន្ទៈ ក៏ឥឡូវនេះ តថាគតជាសាស្តាជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោក ទាំងធម៌សោត

តថាគតបានសម្តែងប្រពៃហើយ ប្រកាសទុកប្រពៃហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រំងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធប្រកាសទុកហើយ ទាំងពួកសាវ័កក៏តថាគតបានពន្យល់ ឱ្យដឹងច្បាស់សេចក្តីក្នុងព្រះសទ្ធម្មហើយ ទាំងព្រហ្មចរិយធម៌ដ៏បរិបូណ៌សព្វគ្រប់ ក៏តថាគតបានធ្វើឱ្យជាក់ច្បាស់ដល់សាវ័កទាំងនោះ ធ្វើឱ្យងាយឡើង ធ្វើឱ្យមានបទរួបរួម ធ្វើឱ្យមានបាដិហារ្យ គឺថាជាធម៌នាំអ្នកបដិបត្តិឱ្យចេញចាកទុក្ខបាន រហូតដល់ពួកទេវតានិងមនុស្សទាំងឡាយ សម្តែងបានដោយប្រពៃ ។

ម្នាលចុន្ទ: ឥឡូវនេះ តថាគត ក៏ជាសាស្តា ជាថេរៈ អ្នកដឹងរាត្រី បួសយូរ តាំងនៅអង្វែង ចម្រើនវ័យដោយលំដាប់ហើយ ។

ម្នាលចុន្ទ: ក្នុងកាលឥឡូវនេះ តថាគត មានពួកភិក្ខុជាថេរៈជាសាវ័ក ជាអ្នកឈ្លាសវៃដឹកនាំក្លៀវក្លា ដល់នូវធម៌ក្សេមចាកយោគៈ អាចប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឱ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយ ជាពាក្យប្រកបដោយធម៌ ហើយសម្តែងធម៌ព្រមទាំងបាដិហារ្យបាន ។

ម្នាលចុន្ទ: ក្នុងកាលឥឡូវនេះ តថាគត មានពួកភិក្ខុជាន់កណ្តាលជាសាវ័កផង ។ ... មានពួកភិក្ខុខ្ចីជាសាវ័កផង ។ ...

មានពួកភិក្ខុនីចាស់ជាសាវិកាផង ។... មានពួកភិក្ខុនីជាន់កណ្តាលជាសាវិកាផង ។ ... មានពួកភិក្ខុនីខ្ចីជាសាវិកាផង ។ ... មានពួកគ្រហស្ថជាឧបាសក មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវ័កផង ។ ... មានពួកគ្រហស្ថជាឧបាសក មានសម្លៀក-បំពាក់ស បរិភោគកាម ជាសាវ័កផង ។ ... មានពួកគ្រហស្ថជាឧបាសិកា មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវិកាផង ។ ... មានពួកគ្រហស្ថជាឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាម ជាសាវិកាផង ។

ម្នាលចុន្ទៈ ឥឡូវនេះ ព្រហ្មចរិយធម៌របស់តថាគត ក៏មាំមួនផ្សាយទូលាយទៅ មានអ្នកចេះដឹងច្រើនក្រាស់ក្រែល ទាំងពួកទេវតានិងមនុស្ស ក៏សម្តែងបានដោយប្រពៃហើយ ។

ទំព័រ ២៥៨ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលចុន្ទៈ ព្រោះហេតុនោះ ធម៌ទាំងឡាយណា ដែលតថាគតបានត្រាស់ដឹង សម្តែងទុកល្អហើយ ក្នុងលោកនេះ គួរឱ្យអ្នកទាំងអស់រួមគំនិត មកប្រជុំរួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈក្នុងធម៌នោះ ដែលជាហេតុឱ្យព្រហ្មចារ្យនេះ តាំងនៅមាំ ឋិតថេរអស់កាលយូរ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន

ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្ស ទាំងឡាយ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់នូវធម៌ទាំងឡាយនោះ គឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋាន ៤ ជាខាងដើម មានអរិយមគ្គអង្គ ៨ ជាខាងចុង ។ ម្នាលចុន្ទៈ ពួកអ្នកនោះឯង ជាអ្នកព្រមព្រៀងគ្នា ជាអ្នកមានចិត្តរីករាយ មិនទាស់ទែងគ្នា គប្បីសិក្សាចុះ ។

ទំព័រ ២៦៤ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលចុន្ទៈ តថាគតសម្តែងធម៌ ដើម្បីរារាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង ដើម្បីកម្ចាត់បង់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ។

- អាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន អដ្ឋកថា ប្រាប់ថា អាសវៈទាំងឡាយដែលកើតឡើង ព្រោះមានបច្ច័យជាហេតុ (ដីកាប្រាប់ថា ការស្វែងរកនិងការបរិភោគនូវបច្ច័យ ៤ ជាហេតុ ) ។

- អាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខ អដ្ឋកថាប្រាប់ថា អាសវៈទាំងឡាយដែលកើតឡើងព្រោះមានការឈ្លោះប្រកែកទាស់ទែងគ្នា ( **ភណ្ឌនៈ** ) ។

- **អាសវានំ សំវរាយ** គឺដើម្បីបិទ បានដល់ មិនឱ្យ

អាសវៈទាំងនោះចូលមកបាន ។

- **អាសវានំ បដិឃាតាយ** គឺដើម្បីកម្ចាត់ ដោយការទម្លាយបូសគល់ នូវអាសវៈទាំងឡាយនេះ ។

- ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងអំពីការពិចារណាបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម ។

- ព្រះអង្គ ទ្រង់ត្រាស់សម្ដែងអំពីសុខល្លិកានុយោគ គឺប្រកបខ្លួនឱ្យប្រព្រឹត្តទៅក្នុងការស្រួល ៤ យ៉ាង ជារបស់ថោកទាប មិនប្រកបដោយប្រយោជន៍ និង សុខល្លិកានុយោគ ៤ យ៉ាង ផ្សេងទៀត ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន សម្រេចបានជាព្រះអរិយបុគ្គល ។

- ព្រះអង្គទ្រង់សម្ដែងអំពីព្រះខីណាស្រព មិនប្រព្រឹត្តកន្លងនូវឋានៈទាំងឡាយ ៩ យ៉ាង ។

- ព្រះអង្គទ្រង់សម្ដែងអំពីព្រះញាណរបស់ព្រះអង្គ ដែលមិនមានអ្វីមករារាំង សម្រេចដល់ព្រះអង្គនៅនាគល់ព្រះពោធិ-ព្រឹក្ស ពេលត្រាស់ដឹងនោះឯង ។

- ព្រះតថាគត ត្រាស់សម្ដែងតែពាក្យក្នុងកាលគួរ ពាក្យសច្ចៈ ពាក្យពិត ពាក្យជាប្រយោជន៍ ពាក្យជាធម៌ ពាក្យជាវិន័យក្នុងធម៌ទាំងឡាយគ្រប់កាលទាំងបី ។

- ព្រះតថាគត ត្រាស់ដឹងហើយដោយប្រពៃ នូវអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ។

- ព្រះតថាគត សម្តែងប្រាប់ ចង្អុលបង្ហាញ នូវហេតុណាក្នុងរវាងការត្រាស់ដឹងនិងបរិនិព្វាន ហេតុទាំងអស់នោះ សុទ្ធតែពិត មិនត្រឡប់ទៅជាដទៃឡើយ ។

- ព្រះតថាគត ត្រាស់យ៉ាងណា តែងធ្វើយ៉ាងនោះ ធ្វើយ៉ាងណា តែងត្រាស់យ៉ាងនោះ ។

- ព្រះតថាគត ជាបុគ្គលដ៏លើសលប់ មិនមានបុគ្គលដទៃគ្របសង្កត់បាន ទ្រង់ចង្អុលបង្ហាញនូវហេតុពិត ទ្រង់ផ្សាយនូវអំណាចទៅក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក សមណព្រាហ្មណ៍ និងពពួកសត្វ ព្រមទាំងមនុស្ស ជាសម្មតិទេព ។

- ព្រះដ៏មានព្រះភាគ មិនព្យាករនូវពាក្យដែលមិនប្រព្រឹត្តទៅដើម្បីវិបស្សនា មិនប្រព្រឹត្តទៅដើម្បីអរិយមគ្គ និងមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានឡើយ ប៉ុន្តែទ្រង់ព្យាករនូវអរិយសច្ចទាំង ៤ គឺធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិបី វៀរតណ្ហា ព្រះអង្គទ្រង់ព្យាករថា នេះជាទុក្ខសច្ច ឯចំណែកតណ្ហាជាហេតុឱ្យកើត ឱ្យចម្រើនឡើងនូវទុក្ខនោះឯង ព្រះអង្គទ្រង់ព្យាករថា នេះជាទុក្ខ-

សមុទយសច្ច។ ការមិនប្រព្រឹត្តទៅនៃសច្ចៈទាំងពីរនោះ គឺទុក្ខសច្ច និងទុក្ខសមុទយសច្ច ព្រះដ៏មានព្រះភាគទ្រង់ព្យាករថាជាទុក្ខ-និរោធសច្ច ឯចំណែកអរិយមគ្គ គឺការកំណត់ដឹងទុក្ខ ការលះសមុទ័យ និងការធ្វើឱ្យជាក់ច្បាស់នូវនិរោធ ព្រះអង្គទ្រង់ព្យាករថា នេះជាទុក្ខនិរោធគាមិនីបដិបទា បានដល់មគ្គសច្ចហ្នឹងឯង ។

- ខាងចុងនៃព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់សម្តែងសតិប្បដ្ឋាន ៤ ជាធម៌សម្រាប់លះបង់នូវមិច្ឆាទិដ្ឋិទាំងអស់ ។

សម័យនោះឯង ព្រះឧបទានដ៏មានអាយុ ឈរបក់ព្រះដ៏-មានព្រះភាគ បានក្រាបទូលព្រះអង្គអំពីសេចក្តីអស្ចារ្យ និងគួរឱ្យជ្រះថ្លាណាស់ ចំពោះធម្មបរិយាយនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធម្មបរិយាយនេះ ជា **បាសាទិកសូត្រ** ។

**សូមអនុមោទនា !**

## ជ្រះថ្លាក្នុងចិត្ត

សេចក្តីជ្រះថ្លា ជាកម្លាំងចិត្ត ដែលធ្វើឱ្យចិត្តមានសុខភាពល្អ និងចម្រើនទៅដោយការងារជាប្រយោជន៍ ម្យ៉ាងទៀត សេចក្តីជ្រះថ្លាគឺជាអនវជ្ជសុខ បានដល់សេចក្តីសុខដែលប្រាសចាក

ទោស សុខក្នុងចិត្ត ជាមនោកម្មនាំឱ្យមានវិបាកជាសុខ មិនត្រឹមតែប៉ុណ្ណោះ សេចក្តីជ្រះថ្លាក្នុងព្រះរតនត្រ័យ គឺជាបាទនៃលោកុត្តរធម៌ទៀតផង ។

អ្នកដែលមានបញ្ញា មានសេចក្តីជ្រះថ្លាជាភូមិឋាន គ្រាន់តែគិតប៉ុណ្ណោះ ក៏បានសេចក្តីសុខសម្រាប់រស់នៅទៅហើយ មានចាំបាច់ទៅធ្វើបាប ចិញ្ចឹមជីវិតខុស និងឈ្លោះទាស់ទែងអី រស់នៅដោយសម្មាអាជីវោ ។

លោកនៃការរស់នៅ គឺជាអារម្មណ៍របស់ចិត្ត បើត្រឹមតែចិត្តដឹងអារម្មណ៍ប៉ុណ្ណោះ តើមានអ្វីជារបស់យើង មានអ្វីជាយើង មានអ្វីជាខ្លួនយើង ។

ចិត្តជាធម្មជាតិ តែងដឹងអារម្មណ៍ល្អ ឬមិនល្អជាធម្មតា ដូចផែនដីជាទីរងទទួលរបស់ល្អ ឬមិនល្អជាធម្មតា ដូច្នោះ ឱ្យតែចិត្តប្រាកដលក្ខណៈត្រឹមតែជាចិត្តប៉ុណ្ណោះ នេះជាចិត្តានុបស្សនា-សតិប្បដ្ឋាន ជាដំណើរចេញចាកលោក ។

# ព្រះសុត្តន្តបិដកខ្មែរលេខ ១៩

## ទីឃនិកាយ បាដិកវគ្គ មាន ៥ ព្រះសូត្រ គឺ

១- លក្ខណសូត្រ ២- សិង្គាលកសូត្រ

៣- អាដានាដិយសូត្រ ៤- សង្គីតិសូត្រ

៥- ទសុត្តរសូត្រ

## ពាក្យគួរយល់ដឹង

≈≈≈≈≈≈≈≈≈≈≈≈≈≈≈

ទេសនា សាសនា កថា នៃព្រះសូត្រ :

- វោហារទេសនា សម្តែងដោយបញ្ញត្តិសព្ទ
- យថានុលោមសាសនា ទូន្មានតាមអធ្យាស្រ័យ
- ទិដ្ឋិវិនិវេឋនកថា ពោលដោះទិដ្ឋិ ៦២ ។

# ១~ លក្ខណសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គត្រាស់សម្ដែងអំពីមហាបុរសប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ។

## មហាបុរិសលក្ខណៈ ៣២ ប្រការ

១- ផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ

២- ផ្ទៃព្រះបាទទាំងគូខាងក្រោមមានរូបចក្រ

៣- ព្រះបណ្ហិគីកែងព្រះបាទវែង

៤- ព្រះអង្គុលីគឺម្រាមព្រះបាទនិងព្រះហស្តវែងៗ

៥- ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទទន់ល្មើយ

៦- ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទប្រទាក់ដោយក្រឡា

៧- មានព្រះបាទដូចជាអណ្ដែតឡើងខាងលើ

៨- ព្រះជង្ឃាគឺស្មងរៀវមូលត្រសូល

៩- ទ្រង់ឈរ អាចស្ទាបអង្អែលព្រះជាណុគឺជង្គង់ ដោយផ្ទៃព្រះហស្តទាំងពីរបាន ។

១០- វត្ថគុយ្ហៈ ឋិតនៅក្នុងស្រោម

១១- ព្រះឆវីវណ្ណ ដូចសម្បុរនៃមាស

១២- ព្រះឆវីវណ្ណ ផូរផង់ មិនជាប់ដោយធូលី

១៣- ព្រះលោមា ក្នុងរណ្តៅមួយ មានតែមួយសរសៃ

១៤- ព្រះលោមា ងឡើងលើជាទក្ខិណាវដ្ត ពណ៌ខៀវស្រស់ ដូចជាពណ៌នៃផ្កាអញ្ជន ។

១៥- ព្រះកាយត្រង់ ដូចជាកាយព្រហ្ម

១៦- ព្រះមំសៈ ៧ កន្លែងពេញលេញបរិបូណ៌ គឺខ្នងព្រះ-ហស្ត ខ្នងព្រះបាទ ចង្កួយស្មា និងព្រះសូរង ។

១៧- ព្រះកាយពាក់កណ្តាលខាងលើ ដូចកាយរាជសីហ៍

១៨- ព្រះបិដ្ឋិគឺខ្នងពេញស្មើបរិបូណ៌

១៩- កម្ពស់ព្រះកាយនិងព្យាមប្រវែងគ្នា ដូចជាបរិមណ្ឌលនៃដើមជ្រៃ ។

២០- ព្រះខន្ធប្បទេសគឺព្រះសូរងមូលសម

២១- សរសៃប្រសាទសម្រាប់ទទួលរសអាហារឆ្ងារល្អិតល្អ

២២- ព្រះហនុគឺចង្កា ដូចចង្ការាជសីហ៍

២៣- ព្រះទន្តចំនួន ៤០ គត់

២៤- ព្រះទន្តរាបស្មើល្អ

២៥- ព្រះទន្តមានរបៀបជិតស្និទ្ធល្អ

២៦- ព្រះទាឋាគឺចង្កូមទាំង ៤ ភ្លឺស្វាត

២៧- ព្រះជិវ្ហាគឺអណ្តាតធំវែង

២៨- ព្រះសូរសៀងក្រាងក្រអៅ ដូចសំឡេងមហាព្រហ្ម បញ្ចេញព្រះវាចាពីរោះ ដូចសំឡេងសត្វករវិក ។

២៩- ព្រះនេត្រខៀវស្រស់ដូចពណ៌ផ្កាត្រកៀត

៣០- ដួងព្រះនេត្រ ដូចដួងភ្នែកកូនគោ

៣១- ព្រះឧណ្ណាលោម គឺរោមដុះចន្លោះចិញ្ចើម មានពណ៌សក្បុស ទន់ដូចសំឡី ។

៣២- ព្រះសីសៈ ដូចប្រដាប់ដោយក្បាំងព្រះភក្ត្រ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីបុណ្យបារមីជាបុព្វកម្មដែលនាំឱ្យសម្រេចបាននូវមហាបុរិសលក្ខណៈ ៣២ ប្រការនេះ ដោយព្រះអង្គទ្រង់ត្រាស់ចែកជា ២០ ចំណែកដូចតទៅ :

**ចំណែកទី ១** គឺព្រះតថាគតជាមនុស្សក្នុងជាតិមុនៗ តែងព្រេកអរក្នុងវចីសច្ចផង ក្នុងធម៌គឺកុសលកម្មបថ ១០ ផង ក្នុងការទូន្មាននូវឥន្ទ្រិយផង ក្នុងសេចក្តីសង្រួមផង ក្នុងការសម្អាតផ្លូវ-កាយជាដើម មានសីលជាទីអាស្រ័យនៃសមថវិបស្សនា ព្រមទាំងឧបោសថកម្មផង ក្នុងកិរិយាមិនបៀតបៀនសត្វទាំងឡាយផង ក្នុង

អំពើដែលមិនរួសរាន់ (ដោយកិលេស ) ផង សមាទានមាំទាំ ប្រព្រឹត្តគ្រប់ទាំងអស់ ។ ព្រោះកម្មនោះឯង ទើបតថាគតបាន ទៅកាន់ស្ថានសួគ៌ សោយសេចក្តីសុខ សេចក្តីសម្រាន្ត និងសេចក្តី ត្រេកអរ លុះច្យុតចាកស្ថានសួគ៌នោះ បានមកកើតក្នុងមនុស្ស-លោកនេះវិញ ក៏មានផ្ទៃព្រះបាទទាំងគូរាបស្មើល្អ (លក្ខណៈទី១)។

**ចំណែកទី ២** គឺព្រះតថាគតកើតជាមនុស្សក្នុងជាតិមុនៗ ជាអ្នកនាំនូវសេចក្តីសុខមកឱ្យដល់ជនច្រើននាក់ ជាអ្នកបន្ទោបង់នូវភ័យគឺសេចក្តីភ្ញាក់ផ្អើលនិងសេចក្តីតក់ស្លុត ជាអ្នកខ្វល់ខ្វាយក្នុងការគ្រប់គ្រងរក្សា ការពារ ។ ព្រោះកម្មនោះ តថាគតបានទៅកាន់ស្ថានសួគ៌ ហើយសោយសេចក្តីសុខ សេចក្តីសម្រាន្ត និងសេចក្តីត្រេកអរ លុះច្យុតចាកស្ថានសួគ៌នោះមក តថាគតបានកើតនៅក្នុងមនុស្សលោកនេះទៀត ក៏បាននូវរូបចក្រត្រង់ផ្ទៃព្រះបាទទាំងពីរ ប្រកបដោយខ្នងកង់និងដុំ ព្រមទាំងកាំមួយពាន់មានចន្លោះស្មើគ្នា (ជាលក្ខណៈទី ២ ) ។

**ចំណែកទី ៣** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ ដឹងច្បាស់នូវភ័យអំពីសេចក្តីស្លាប់ ដែលហៅថាមរណៈចំពោះខ្លួនឯង ហើយ បានវៀរស្រឡះចាកការសម្លាប់សត្វដទៃ ។ ព្រោះអំពើសុចរិតនេះឯង តថាគតបានកើតក្នុងស្ថានសួគ៌ សោយផលវិបាក

របស់កម្មដែលបានធ្វើទុកល្អហើយ ។ លុះច្យុតចាកទេវលោកនោះ បានមកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវលក្ខណៈទាំង ៣ នេះ ក្នុងភពនេះ គឺជាអ្នកមានកែងជើងវែងទូលាយ ១ (លក្ខណៈទី ៣) មានកាយត្រង់ល្អស្អាត ដូចជាកាយព្រហ្ម មានភ្នែកល្អ មានរូបនៅក្មេង មានទ្រង់ទ្រាយល្អ មានជាតិល្អ ១ (លក្ខណៈទី ១៥) និងមានព្រះអង្គុលីទន់ល្វន់វែងៗល្អ ១ (លក្ខណៈទី ៤) ។

**ចំណែកទី ៤** គឺព្រះតថាគតកើតជាមនុស្សក្នុងជាតិមុនៗ ជាអ្នកឱ្យនូវខាទនីយភោជនីយាហារ និងទឹកដែលគួរលិទ្ធ គួរភ្លក្សដែលមានរសជាតិដ៏ឧត្តមថ្លៃថ្លា ។ ព្រោះសុចរិតកម្មនោះ ទើបតថាគតរីករាយក្នុងឧទ្យាននន្ទវន័ អស់កាលយូរ ។ លុះច្យុតមកកើតក្នុងមនុស្សលោកនេះ ក៏បាននូវសាច់ដ៏ពេញក្នុងទីទាំង ៧ កន្លែង ទាំងផ្ទៃព្រះហស្តនិងព្រះបាទ ក៏ទន់ល្វន់ផង (ជាលក្ខណៈទី ១៦) ។

**ចំណែកទី ៥** គឺព្រះតថាគតជាមនុស្សក្នុងជាតិមុនៗ បានធ្វើហើយ បានប្រព្រឹត្តនូវការសង្គ្រោះដោយល្អ ដល់ពួកជនច្រើននាក់ ដោយសង្គហវត្ថុ ៤ ប្រការ បានដល់ទាន ១ ការប្រព្រឹត្តឱ្យជាប្រយោជន៍ ១ ពាក្យជាទីស្រឡាញ់ ១ មានឆន្ទៈក្នុងការតាំងខ្លួនស្មើ ១ ទើបទៅកាន់ស្ថានសួគ៌ដោយគុណ គឺការមិនប្រមាទ

មិនមើលងាយ ។ លុះតថាគតច្យុតចាកស្ថានសួគ៌នោះ មកកើតក្នុងភពនេះទៀត ក៏បាននូវលក្ខណៈទាំងពីរនេះ គឺជាអ្នកមានផ្ទៃព្រះហស្ត ផ្ទៃព្រះបាទទន់ល្វន់ ដូចជាសំឡីដែល គេថ្ពេចអស់ ១០០ ដង ១ (លក្ខណៈទី ៥ ) និងមានផ្ទៃព្រះហស្ត ផ្ទៃព្រះបាទប្រទាក់ដោយក្រឡា ដូចជាសំណាញ់ ១ (លក្ខណៈទី ៦ ) ។

**ចំណែកទី ៦** គឺព្រះតថាគតជាមនុស្សក្នុងជាតិមុនៗ បានពិចារណាជាមុនរួចហើយ ទើបពោលពាក្យដែលប្រកបដោយអត្ថទាំងប្រកបដោយធម៌ បានពន្យល់ប្រយោជន៍ដល់ជនច្រើននាក់ ជាអ្នកបាននាំមកនូវប្រយោជន៍និងសេចក្តីសុខ ឱ្យដល់សត្វទាំងឡាយ ជាអ្នកមិនមានសេចក្តីកំណាញ់ បានចាត់ចែងនូវការបូជាធម្មទាន។ ព្រោះសុចរិតកម្មនោះឯង តថាគតបានទៅកាន់ សុគតិនោះ លុះដល់មកកើតក្នុងភពនេះ ក៏បាននូវលក្ខណៈទាំងពីរ ដើម្បីភាពនៃសេចក្តីសុខដ៏ឧត្តម ។ តថាគតមានព្រះបាទ ដូចជាអណ្តែតឡើងលើ មានសន្ទាក់កជើងប្រតិស្ឋានល្អ មានសាច់និងឈាមប្រផូរ បិទបាំងដោយស្បែក និងមានជង្គង់ល្អ (លក្ខណៈទី ៧ ) លក្ខណៈម្យ៉ាងទៀត គឺមានព្រះលោមា ងឡើងលើជាទក្ខិណាវដ្តវិលវង់ព័ទ្ធពេនទៅខាងស្តាំ កួចមូលដូចជាកុណ្ឌល និងមានពណ៌ខៀវ ដូចជាពណ៌នៃផ្កាអញ្ជ័ន (លក្ខណៈទី ១៤ ) ។

**ចំណែកទី ៧** គឺព្រះតថាគតជាមនុស្សក្នុងជាតិមុនៗ តែងប្រាថ្នាដូច្នេះថា ធ្វើម្ដេចហ្ន៎ ជនទាំងឡាយនេះ នឹងចេះដឹងនូវសិល្បសាស្ត្រ វិជ្ជា ចរណៈ និងការងារទាំងឡាយ បានដោយឆាប់រហ័ស ឯសិល្បសាស្ត្រណា មិនបៀតបៀនដល់អ្នកណាមួយ តថាគតបានបង្រៀននូវសិល្បសាស្ត្រនោះ យ៉ាងឆាប់រហ័ស មិនឱ្យលំបាកអស់កាលយូរឡើយ ។ ព្រោះតថាគត បានធ្វើកុសលកម្មនោះ ដែលជាកម្មញ៉ាំងសុខឱ្យចម្រើន ទើបបាននូវព្រះជង្ឃាគឺស្មងដ៏ល្អ រៀវមូល ដូចជាស្មងនៃសត្វទ្រាយ (លក្ខណៈទី ៨) ។

**ចំណែកទី ៨** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ ជាអ្នកចង់ចេះ ចង់ដឹង បានចូលទៅរកបព្វជិត ហើយសាកសួរនូវប្រស្នា បានស្ដាប់ដោយគោរព ធ្វើសេចក្ដីឱ្យតាំងនៅខាងក្នុង ហើយចំណាំនូវពាក្យ ដែលប្រកបដោយប្រយោជន៍តែម្យ៉ាង ។ ព្រោះកម្មដែលប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញានោះ ទើបតថាគតកើតមកជាមនុស្ស មានព្រះឆវីដ៏ល្អិតផូរផង់ រលីងស្រិល រអិលធូលីធ្លាក់មក គឺធូលីមិនជាប់ព្រះកាយឡើយ (លក្ខណៈទី ១២) ។

**ចំណែកទី ៩** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ បានអធិដ្ឋានទុកនូវសេចក្ដីមិនក្រោធផង នូវទានផង ហើយបានឱ្យនូវសំពត់ទាំងឡាយ មានសាច់ម៉ដ្ឋ មានពណ៌ស្រស់ ។ តថាគត ឋិត

នៅក្នុងភពមុនៗ បានបរិច្ចាគទាន ហាក់ដូចជាទឹកភ្លៀងដែលធ្លាក់ចុះមកលើផែនដី ដូច្នោះឯង ព្រោះកុសលកម្មនោះ តថាគតច្យុតចាកមនុស្សលោក បានចូលទៅកាន់ទិព្វវិមាន បានសោយផលវិបាកនៃអំពើដែលខ្លួនបានធ្វើហើយ ជាអ្នកមានពណ៌សម្បុរកាយដូចមាស លុះច្យុតមកកើតក្នុងភពនេះ បានគ្របសង្កត់នូវមនុស្សទាំងអស់ដោយពណ៌សម្បុរមាសភ្លឺបំព្រង (លក្ខណៈទី ១១) ដូចជាព្រះឥន្ទដែលប្រសើរជាងពួកអសុរ ដូច្នោះឯង ។

**ចំណែកទី ១០** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ បានរាប់អាននូវញាតិ មិត្ត និងសម្លាញ់ស្និទ្ធស្នាល ដែលព្រាត់ប្រាសនិរាសបាត់មុខ អស់កាលយូរហើយផង ជាអ្នកត្រេកអរក្រៃលែងព្រោះបានធ្វើគេឱ្យព្រមព្រៀងគ្នាផង ។ ព្រោះកម្មនោះ តថាគតបានទៅកាន់ស្ថានសួគ៌ សោយសេចក្ដីសុខសម្រាន្ត និងសេចក្ដីត្រេកអរ លុះច្យុតចាកស្ថានសួគ៌នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវវត្ថុគុយ្ហៈដ៏កំបាំងក្នុងស្រោម ជាអង្គាវយវៈដែលគេត្រូវបិទបាំងដោយសំពត់ (លក្ខណៈទី ១០) ។

**ចំណែកទី ១១** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ បានលៃលក ពិចារណា គិតហើយទើបសម្លឹងមើលនូវការសង្គ្រោះដល់មហាជនដោយស្មោះស្មើ ជាអ្នកបានធ្វើនូវគ្រឿងសក្ការៈ

តម្រូវតាមគុណវិសេសនៃបុរសនោះៗ ក្នុងកាលមុនថា បុរសនេះ គួរបាននូវទានជាគ្រឿងសក្ការៈនេះ ។ ព្រោះកុសលកម្មនោះ តថាគតបានទៅកាន់ទេវលោក លុះច្យុតចាកស្ថានសួគ៌មកក្នុង អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈពីរ គឺជាអ្នក មានបរិមណ្ឌលនៃកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ ១ (លក្ខណៈ ទី ១៩ ) និងកាលបើឈរដោយមិនបាច់ឱនខ្លួនចុះ អាចស្ទាបប៉ះ ពាល់ព្រះជាណុដោយព្រះហស្តទាំងពីរបាន ១ (លក្ខណៈទី ៩ ) ។

**ចំណែកទី ១២** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ តែង ប្រាថ្នា និងប៉ុនប៉ងនូវភាពមាំមួននិងសេចក្តីចម្រើន ដល់ពួកជន ដទៃថា ធ្វើដូចម្តេច កុំឱ្យជនទាំងឡាយសាបសូន្យចាកសទ្ធា សីល សុតៈ ចាគៈ បញ្ញា លោកិយធម៌ ព្រមដោយគុណ គឺសេចក្តីល្អ ច្រើនប្រការទៀត និង ទ្រព្យធន ធញ្ញាហារ ស្រែចម្ការ កូនប្រពន្ធ សត្វជើង ២ សត្វជើង ៤ ញាតិ មិត្ត ផៅពង្ស ព្រមទាំងកម្លាំង ពណ៌សម្បុរកាយ សេចក្តីសុខទាំងពីរប្រការ ។ ព្រោះកុសលកម្ម នោះ ដែលតថាគតបានធ្វើ បានសន្សំ ទើបតថាគតបានទៅកាន់ ទេវលោក លុះតថាគតច្យុតមកកាន់អត្តភាពជាមនុស្សនេះ ក៏បាន នូវមហាបុរិសលក្ខណៈទាំង ៣ នេះ គឺមានចំណែកពាក់កណ្តាល ព្រះកាយខាងលើ រាងស្រដៀងនឹងពាក់កណ្តាលខ្លួនខាងមុខនៃ

រាជសីហ៍ ១ (លក្ខណៈទី ១៧ ) មានព្រះបិដ្ឋិគឺខ្នងពេញស្មើ ឥត
មានចង្អូរផតខ្វងត្រង់កណ្ដាលឡើយ ១ (លក្ខណៈទី ១៨ ) និង
មានព្រះសូរង ដង ក មូលសម ១ (លក្ខណៈទី ២០ ) ។

**ចំណែកទី ១៣** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ ជាអ្នកមិនបានបៀតបៀន មិនបានប្រទូស្តដល់ប្រជុំជន ដោយដៃ ឬដោយដំបង ដោយដុំដី ឬក៏ដោយគ្រឿងសស្ត្រាវុធឡើយ ហើយក៏មិនបានប្រើឱ្យគេសម្លាប់ បៀតបៀន ចាប់ចង សម្លុតគំរាមឱ្យអ្នកណាៗភ័យខ្លាចនោះដែរ ។ ព្រោះកម្មនោះឯង ទើបតថាគតចាកមនុស្សលោកទៅ បានរីករាយក្នុងស្ថានសួគ៌ ដល់នូវសេចក្ដីសុខ ព្រោះធ្វើអំពើដែលមានផលជាសុខ ។ លុះមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវប្រសាទគឺសរសៃល្អិតឆ្មារដ៏ក្រៃលែងសម្រាប់ទទួលរសអាហារ ប្រជុំស្រោបព្រះសូរង ធ្វើឱ្យអាហារជ្រួតជ្រាបផ្សព្វផ្សាយស្មើគ្នាសព្វសព៌ាង្គកាយ (លក្ខណៈទី ២១ ) ។

**ចំណែកទី ១៤** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ ជាអ្នកមិនសម្លឹងសម្លក់មើលដោយទោសចិត្ត មិនមៀងមើលដោយចុងភ្នែក កន្ទុយភ្នែក ព្រោះដោយចិត្តស្អប់នោះឡើយ ផ្ទុយមកវិញតថាគតជាអ្នកមានចិត្តស្មោះត្រង់ ពេចពិលរមិលមើលត្រង់ពេញភ្នែក គឺជាអ្នកសម្លឹងមើលមហាជន ដោយចក្ខុគួរស្រឡាញ់ ។

តថាគត បានទៅសោយផលវិបាកក្នុងសុគតិ រីករាយក្នុងសុគតិនោះ លុះច្យុតចាកទេវលោក មកកើតក្នុងអត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺមានព្រះនេត្រខៀវស្រស់ ១ (លក្ខណៈទី ២៩ ) និងមានដួងព្រះនេត្រដូចកែវភ្នែកកូនគោ ១ (លក្ខណៈទី ៣០ ) ។

**ចំណែកទី ១៥** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ ជាចម្បងនៃពពួកជន ក្នុងសុចរិតធម៌ទាំងឡាយ ជាអ្នកត្រេកអរក្នុងការប្រព្រឹត្តធម៌ មានជនច្រើននាក់ជាបរិវារ លុះតថាគតចាកលោកមនុស្សនេះទៅ ក៏បានសោយផលនៃបុណ្យក្នុងស្ថានសួគ៌ ។ តថាគត សោយផលនៃសុចរិតនោះហើយ បានច្យុតមកកើតក្នុងមនុស្សលោកនេះ ក៏មានសីសៈហាក់ដូចជា ប្រដាប់ដោយក្បាំងព្រះភក្ត្រស្រេចស្រាប់ (លក្ខណៈទី ៣២ ) ។

**ចំណែកទី ១៦** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ ជាអ្នកកាន់ពាក្យសច្ចៈ មានវាចាគួរជឿ វៀរចាកពាក្យមិនពិត គឺជាអ្នកមិនក្លែងពោលពាក្យមិនពិត ចំពោះជនណាមួយនោះឡើយ និយាយតែពាក្យពិត ទៀងទាត់ត្រឹមត្រូវ ។ ព្រោះកុសលកម្មនេះ ។ល។ លុះតថាគត ច្យុតចាកស្ថានសួគ៌ មកកើតក្នុងអត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរ គឺព្រះលោមា

ក្នុងរណ្ដៅមួយៗ តែមួយសរសៃៗ គ្រប់រណ្ដៅរោមទាំងអស់ ១ (លក្ខណៈទី ១៣ ) និងព្រះឧណ្ណាលោម រោមប្រជុំចិញ្ចើម មានពណ៌សស្អាត ទន់ល្វន់ដូចជាសំឡី ១ (លក្ខណៈទី ៣១ ) ។

**ចំណែកទី ១៧** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ មិនបានពោលពាក្យបង្កហេតុ ឱ្យបែកបាក់ចាកការព្រមព្រៀងគ្នាឡើយ ហើយក៏មិនពោលពាក្យឱ្យគេឈ្លោះទាស់ទែងគ្នា ឬពាក្យដែលឱ្យគេធ្វើអំពើមិនគួរគប្បីអ្វីនោះដែរ តថាគត ពោលតែពាក្យល្អ ជាពាក្យធ្វើសេចក្ដីមិនវិវាទឱ្យចម្រើន និងពាក្យផ្សះផ្សាជនដែលបែក-បាក់គ្នាហើយ ឱ្យព្រមព្រៀងគ្នាវិញ ត្រេកអររីករាយជាមួយគ្នា ។ ព្រោះកុសលកម្មនោះ ។ល។ លុះតថាគតច្យុតចាកស្ថានសួគ៌ មកកើតក្នុងមនុស្សលោកនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺមានព្រះទន្ត ៤០ គត់ ១ (លក្ខណៈទី ២៣ ) និងព្រះទន្តជិតស្និទ្ធល្អ ១ (លក្ខណៈទី ២៥ ) ។

**ចំណែកទី ១៨** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ មិនបានពោលពាក្យអាក្រក់គ្រោតគ្រាត ដែលជាពាក្យជេរ ជាពាក្យបង្កហេតុឱ្យទាស់ទែងគ្នា បៀតបៀនគ្នា ជាពាក្យដែលធ្វើឱ្យឈឺចិត្ត និងជាពាក្យមើលងាយនូវពពួកជនឡើយ ។ តថាគត ពោលតែពាក្យ ដែលជាទីស្រឡាញ់ពេញចិត្ត ផ្អែមល្ហែម ទន់ភ្លន់ ប្រកប

ដោយប្រយោជន៍ គួរតម្កល់ទុកក្នុងហឫទ័យ នាំមកនូវសេចក្ដីសុខ ដល់ត្រចៀកនៃអ្នកដែលបានស្ដាប់ៗ ។ តថាគត បានសោយផល នៃបុណ្យក្នុងស្ថានសួគ៌ បានសោយផលនៃសុចរិតកម្មនោះហើយ ច្យុតមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈ ទាំងពីរ គឺ មាននូវព្រះជិវ្ហាធំវែង ១ (លក្ខណៈទី ២៧ ) និងមាន សំឡេងក្រាងក្រអៅ ដូចជាសំឡេងព្រហ្ម កាលបើបញ្ចេញវាចា ក៏លាន់ឮពីរោះ ដូចសំឡេងសត្វករវិក ១ (លក្ខណៈទី ២៨ ) ។

**ចំណែកទី ១៩** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ មិន ពោលពាក្យឥតប្រយោជន៍ ពាក្យរាយមាយឡើយ តថាគត តែង បន្ទោបង់នូវពាក្យដែលឥតប្រយោជន៍ផង ពោលតែពាក្យដែល មានប្រយោជន៍ ជាពាក្យនាំមកនូវសេចក្ដីសុខដល់ជនដ៏ច្រើន ផង តថាគត ជាអ្នកមានគន្លងនៃពាក្យមិនរាយមាយ ។ ព្រោះ កុសលកម្មនោះ ។ល។ លុះច្យុតចាកស្ថានសួគ៌ មកកាន់អត្តភាព ជាមនុស្សនេះវិញ ក៏មាននូវព្រះហនុគឺចង្កា ដូចជាចង្ការាជសីហ៍ (លក្ខណៈទី ២២ ) ។

**ចំណែកទី ២០** គឺព្រះតថាគត ជាមនុស្សក្នុងជាតិមុនៗ បាន លះបង់ការចិញ្ចឹមជីវិតខុស និងបានបំពេញនូវការចិញ្ចឹមជីវិត ដោយសម្មាអាជីវៈបានស្អាតល្អ ដែលប្រព្រឹត្តទៅជាធម៌ដ៏ស្មោះស្មើ

ផង លះបង់កម្មដែលឥតប្រយោជន៍ ប្រព្រឹត្តនូវកម្មដែលមានប្រយោជន៍ នាំមកនូវសេចក្តីសុខដល់ពពួកជនច្រើនផង ។ តថាគត ជាមនុស្សបានធ្វើនូវអំពើមានផលដ៏ល្អ ដែលពួកសប្បុរសជាអ្នកប្រាជ្ញ មានបញ្ញាល្អិត តែងសរសើរ ហើយទើបសោយនូវសុខក្នុងស្ថានសួគ៌ ស្មើដោយសក្កទេវរាជ ដែលជាអង្គកំពូលលើទេវតាក្នុងឋានតាវត្តិង្ស តែងត្រេកអរមូលមិត្តដោយសេចក្តីរីករាយ និងសេចក្តីសុខសម្រាន្ត ។ លុះតថាគតច្យុតចាកទេវលោក មកកើតជាមនុស្សនេះម្តងទៀត ក៏បាននូវមហាបុរិសលក្ខណៈពីរនេះ គឺព្រះទន្តរាបស្មើល្អ ១ (លក្ខណៈទី ២៤ ) និងព្រះទាឋាទាំង ៤ ភ្លឺស្អាតល្អ ១ (លក្ខណៈទី ២៦ ) ។

ខាងចុងនៃព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ពួកគ្រហស្ថ និងបព្វជិតជាច្រើន ដែលជាអ្នកធ្វើតាមឱវាទរបស់តថាគត តែងជាអ្នកប្រាសចាកសេចក្តីសៅហ្មង ព្រោះថា តថាគតដែលមានបាបបន្សាត់ចោលហើយនោះ រមែងមានតែពួកមនុស្សស្អាតល្អ ដែលជាអ្នកកម្ចាត់បង់នូវមន្ទិល កម្ចាត់បង់នូវដង្គត់គឺរាគាទិក្កិលេស កម្ចាត់បង់នូវទោសមកចោមរោមជុំវិញតថាគត ។

**សូមអនុមោទនា !**

# ពិចារណាការងារ

ការងារសំខាន់ណាស់ ឱ្យសម្រេចបំណងប្រាថ្នាគ្រប់យ៉ាង សូម្បីការត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ក៏បានសម្រេចពីការងារដែរ ការងារជាហេតុនៃសេចក្តីសុខ សេចក្តីសម្រេច ព្រមទាំងការដល់ត្រើយ ។ ព្រោះហេតុដូច្នេះ ត្រូវពិចារណាការងារ កាន់យកតែការងារសុចរិតត្រឹមត្រូវមកជាមិត្ត រួមដំណើរជីវិតរហូតអវសាន ។

ត្រូវប្រយ័ត្នកិលេសក្នុងចិត្តខ្លួនឯង ដែលអូសទាញឱ្យប្រព្រឹត្តកម្មជាទោស ។

ត្រូវគ្រប់គ្រងលោភៈ ដោយសន្តោស គ្រប់គ្រងទោសៈ ដោយសីល និងគ្រប់គ្រងមោហៈ ដោយអប់រំចម្រើនសតិគ្រប់ការងារជាកុសល ។

# ២. សិង្គាលកសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន័ ជិតក្រុងរាជគ្រឹះ ក្នុងសម័យនោះ បុត្រគហបតីម្នាក់ឈ្មោះសិង្គាលកៈ ក្រោកឡើងពីព្រឹក ចេញពីក្រុងរាជគ្រឹះ ប្រណម្យអញ្ជលី ថ្វាយបង្គំទិសទាំងឡាយ ៦ គឺទិសធំ ៤ និងទិសខាងក្រោមផង ទិសខាងលើផង ។

រៀបរាប់រឿងខ្លះ សិង្គាលកមាណពនេះ ជាកូនគហបតីមហាសាល មាតាបិតា មានទ្រព្យ ៤០ កោដិ នៅក្រុងរាជគ្រឹះ ជាព្រះសោតាបន្នបុគ្គលទាំងពីរនាក់ នៅតែសិង្គាលកៈជាកូនប៉ុណ្ណោះ ជាបុថុជ្ជនហើយមិនទាន់មានសទ្ធាក្នុងព្រះរតនត្រ័យទៀត ។ មាតាបិតា តែងតែទូន្មានណែនាំរឿយៗ ឱ្យកូនចូលទៅគាល់ព្រះសាស្តា ចូលទៅរកព្រះអគ្គសាវក័ ព្រះមហាកស្សបៈជាដើម ប៉ុន្តែសិង្គាលកៈជាកូនតបថា ការចូលទៅរកសមណៈទាំងឡាយ មិនមានដល់កូនទេ ព្រោះចូលទៅហើយត្រូវថ្វាយបង្គំវានាំឱ្យឈឺខ្នង ប្រឡាក់ជង្គង់ ចាំបាច់ត្រូវអង្គុយនឹងដីប្រឡាក់សំពត់ចាស់អស់ រួចហើយត្រូវសន្ទនា មានការស្និទ្ធស្នាល ក្រោយ

មកត្រូវនិមន្តឱ្យទទួលចីវរបិណ្ឌបាតជាដើម កាលបើដូច្នេះ រមែង វិនាសប្រយោជន៍ ។ ក្រោយមក បិតាជិតនឹងទទួលមរណភាព បានឱ្យឱវាទដល់កូន ប្រាប់កូនឱ្យថ្វាយបង្គំទិសទាំងឡាយ ដោយ បិតាគិតថា កូននឹងបានទទួលការណែនាំពីព្រះដ៏មានព្រះភាគ ឬ ព្រះអរិយសាវក័ទាំងឡាយ កូននឹងបានដឹងគុណព្រះពុទ្ធសាសនា ហើយបានធ្វើបុណ្យជាទីពឹងតទៅ ។

នៅពេលជិតភ្លឺ ព្រះបរមសាស្តាទ្រង់ពិចារណាសត្វលោក ដោយពុទ្ធចក្ខុ បានទតព្រះនេត្រឃើញសិង្គាលកមាណព កំពុង ថ្វាយបង្គំទិសទាំងឡាយ ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ តថាគត នឹងសម្តែងនូវសិង្គាលកសូត្រ ដែលជាវិន័យរបស់គ្រហស្ថ ដល់ សិង្គាលកគហបតិបុត្រ ព្រះសូត្រនោះ នឹងមានផលដល់មហាជន តថាគតគួរទៅក្នុងទីនោះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែគហបតិបុត្រ ក្នុង វិន័យរបស់ព្រះអរិយៈ គេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាងដូច្នេះ ឡើយ ។ កាលដែលសិង្គាលកមាណពទូលសួរហើយ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់សម្តែងជាបន្តបន្ទាប់រហូតដល់ចប់ ។

ខ្លឹមសារក្នុងព្រះសូត្រគឺ

- អរិយសាវក័ លះបង់នូវកម្មក្កិលេស ៤ យ៉ាង

- អរិយសាវក័ មិនធ្វើបាបកម្មព្រោះអគតិ ៤ យ៉ាង

- អរិយសាវក័ មិនសេពអបាយមុខ ៦ យ៉ាង

- មិត្តប្ញម ៤ ពួក មិត្តមានឧបការៈ ៤ ពួក

- មាតាបិតាជាទិសខាងកើត

- អាចារ្យជាទិសខាងត្បូង

- បុត្រនិងភរិយា ជាទិសខាងលិច

- មិត្តនិងអាមាត្យ ជាទិសខាងជើង

- ទាសៈនិងកម្មករ ជាទិសខាងក្រោម

- សមណព្រាហ្មណ៍ ជាទិសខាងលើ ។

ព្រះដ៏មានព្រះភាគ ទ្រង់ចែកសេចក្ដីនៃព្រះធម៌ ដែលធ្វើឱ្យសិង្គាលកមាណព ស្ដាប់បានយល់ ជ្រះថ្លា ពោលសរសើរព្រះធម៌ទេសនា និងសូមដល់ព្រះរតនត្រ័យជាសរណៈស្មើដោយជីវិត ។

ព្រះពុទ្ធអង្គ ទ្រង់សម្ដែងព្រះធម៌ប្រោសសិង្គាលកមាណពហើយ ស្ដេចយាងចូលកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ សិង្គាលកមាតា បានចូលកាន់ផ្នួស សម្រេចព្រះអរហត្ត ជាឯតទគ្គៈលើភិក្ខុនីទាំងឡាយ ផ្នែកខាងមានសទ្ធាស៊ប់ស្ងួន ។ ចំណែកសិង្គាលកៈតាំងនៅក្នុងសរណៈទាំងឡាយហើយ បានបរិច្ចាគទ្រព្យ

៤០ កោដិ ទុកក្នុងព្រះពុទ្ធសាសនា បំពេញបុណ្យកុសលទៅកាន់ស្ថានសួគ៌ ។

**សូមអនុមោទនា !**

## តួនាទីសំខាន់ណាស់

តួនាទី គឺកិច្ចដែលមនុស្សយើងម្នាក់ៗត្រូវធ្វើ វាជារឿងរបស់ធម្មជាតិ ជាហេតុផលដែលព្រះសម្មាសម្ពុទ្ធពន្យល់ប្រាប់ថា ជោគជ័យនៃជីវិត គឺជាផលនៃការងាររបស់ខ្លួនឯង ។ មនុស្សត្រូវតែគោរពតួនាទី ស្រឡាញ់ការងារ ព្រោះមិនមានអានុភាពអ្វីណា ឬអ្នកណា មកគាំទ្រយើងឱ្យខ្ពង់ខ្ពស់ ក្រៅអំពីខ្លួនឯងដែលគោរពនូវការងាររបស់ខ្លួនឡើយ ។

ព្រះពុទ្ធសាសនា គឺជាសាសនានៃការងារ ជាការងារដែលប្រាសចាកទោស ជាសិរីសួស្តីនៃជីវិត ។ ការងារអ្វីក៏ដោយក៏ត្រូវចាប់ផ្តើមពីដំបូងទៅដែរ ហើយរាល់ការងារទាំងអស់ វាតែងតែមាននូវឧបសគ្គមករារាំងជាធម្មតា ប៉ុន្តែ កាលបើមានព្យាយាមនិងសេចក្តីអត់ធន់ហើយ ការងារនោះរមែងបានសម្រេច

មានលទ្ធផលល្អគួរជាទីគាប់ចិត្ត ផ្ទុយទៅវិញ មនុស្សដែលមិនយកចិត្តទុកដាក់ក្នុងការងាររបស់ខ្លួន មិនខុសពីមនុស្សដែលអត់ការងារនោះឡើយ ហើយមិនយូរប៉ុន្មាន អ្នកនោះនឹងទៅជាមនុស្សបាត់បង់ការងារ ក្លាយទៅជាមនុស្សពិការ ទាំងដែលនៅមានអវយវៈគ្រប់គ្រាន់ ។

មនុស្សអត់ការងារជាមនុស្សអន់ ជាមនុស្សទ្រមក់ ប៉ុន្តែបើមានការងារអាក្រក់ ទុច្ចរិតទៅវិញនោះ ជាមនុស្សគម្រក់តែម្តង ។ ការងារបែងចែកមនុស្សលោកឱ្យខ្ពង់ខ្ពស់ ឬថោកទាបដូច្នេះ សូមមនុស្សទាំងឡាយ ខំប្រឹងប្រែងលះបង់នូវការងារណាដែលសៅហ្មង ថោកទាប ហើយព្យាយាមក្នុងការងារដែលបរិសុទ្ធប្រាសចាកទោស ជាមនុស្សគំរូល្អ ហើយបានសប្បាយចិត្តជានិច្ចដោយមកពីបានពិចារណាឃើញអំពើដ៏បរិសុទ្ធរបស់ខ្លួន ។

ខ្លាចលំបាកហើយខ្ជិលមិនព្យាយាម មិនរួចពីសេចក្តីទុក្ខលំបាកឡើយ ។

ខ្វះសេចក្តីអត់ធន់ ការងារមិនបានល្អ ។

ខ្វះការតស៊ូ ការងារមិនបានសម្រេច ។

រវល់តែរឿងស្នេហា កាន់ការងារធំមិនបាន ។

ព្រោះតែប្រហែសធ្វេស ការងារដែលចេះស្ទាត់ហើយនោះ

ត្រឡប់ទៅជាបរាជ័យ ដូចបុគ្គលល្ងង់ខ្លៅ ។

មិនបំពេញតួនាទី ឈ្មោះថាស្លាប់ទាំងរស់ បែរទៅធ្វើបាបវិញនោះ ឈ្មោះថាស្អុយទាំងស្រស់ ។

បាននៅរស់ហើយ គួរតែចេះស្កប់ស្កល់ អ្វីៗមិនមែនចេះតែបានតាមចិត្តចង់ទេ បើចេះតែបានតាមការទាមទារ មិនមានអ្នកស្លាប់ឡើយ ។ ពិតមែនថា មិនទាន់ស្លាប់ ប៉ុន្តែជីវិតឋិតនៅក្នុងអំណាចបច្ច័យយ៉ាងត្រឹមត្រូវ ដូច្នេះត្រូវដោះស្រាយបញ្ហាដោយការចិញ្ចឹមជីវិតប្រកបដោយធម៌ ធ្វើតែការងារល្អៗ សាងហេតុនៃសេចក្ដីសុខស្ងប់ឱ្យដល់ខ្លួន និងអ្នកដទៃ ។

## ត្រូវចិត្តនិងត្រូវត្រង់

កុំចេះតែចង់ឱ្យត្រូវចិត្ត សិក្សាការពិតឱ្យត្រូវត្រង់
ត្រូវចិត្តចម្រើនតែចំណង់ ត្រូវត្រង់ការពិតចិត្តសុខស្ងប់ ។

# ៣_ អាដានាដិយសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះ ទេវរាជទាំង ៤ អង្គ មានស្តេចវេស្សវណ្ណជាដើម បានតាំងការរក្សាក្នុងទិសទាំង ៤ ដើម្បីការពារអសុរ កុំឱ្យឡើងមករំខានដល់សក្កទេវរាជ ។ ទិសទាំង ៤ នៃភ្នំសិនេរុ ច្រើនដោយសេនាយក្ស សេនាគន្ធព្វ សេនាកុម្ភណ្ឌ និងច្រើនដោយសេនានាគ ។ ទេវរាជទាំង ៤ អង្គ គង់ប្រថាប់នៅក្នុងអាដានាដានគរ ប្រារព្ធដល់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ មានព្រះវិបស្សីសម្មាសម្ពុទ្ធជាដើម ហើយបានចងក្រងនូវព្រះបរិត្តក្នុងនគរនោះឯង ទើបព្រះសូត្រនេះ ឈ្មោះអាដានាដិយសូត្រ ។

កាលដែលទេវរាជទាំង ៤ ចងក្រងនូវព្រះបរិត្តនេះរួចហើយ បាននាំគ្នាចូលមកគាល់ព្រះដ៏មានព្រះភាគនៅនាព្រះគន្ធកុដិ លើភ្នំគិជ្ឈកូដហ្នឹងឯង បានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគដោយគោរព ហើយគង់ប្រថាប់ក្នុងទីដ៏សមគួរ ។

នៅក្នុងព្រះសូត្រនេះ ពួកទេវតាអង្គុយ ព្រោះដោយ

សេចក្ដីគោរពដល់ព្រះបរិត្ត ។ ពួកយក្សជាបរិវារខ្លះថ្វាយបង្គំព្រះដ៏មានព្រះភាគដោយគោរព ពួកខ្លះ គ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះដ៏មានព្រះភាគ ពួកខ្លះគ្រាន់តែអង្គុយប្រណម្យអញ្ជលី ចំពោះព្រះដ៏មានព្រះភាគ ពួកខ្លះគ្រាន់តែប្រកាសនាមនិងគោត្រ ឯពួកយក្សខ្លះទៀត គ្រាន់តែអង្គុយស្ងៀម ក្នុងទីដ៏សមគួរប៉ុណ្ណោះ ។

ទេវរាជទាំង ៤ ស្ដេចមកទាំងអស់អង្គក៏ពិត ប៉ុន្តែស្ដេចវេស្សវណ្ណជាបុគ្គលស្និទ្ធស្នាលនៃព្រះទសពល ឆ្លាតក្នុងការក្រាប-ទូល មានការសិក្សាយ៉ាងល្អ ព្រោះដូច្នោះ ទើបស្ដេចវេស្សវណ្ណ-មហារាជ បានជាអ្នកក្រាបទូលដល់ព្រះដ៏មានព្រះភាគ នូវអាដា-នាដិយបរិត្តក្នុងព្រះសូត្រនេះឯង ។ មហារាជអង្គនេះ កាលដែលនៅជាមនុស្ស មាននាមថា **កុវេរះ** ជាព្រាហ្មណ៍ បានសាងរោងគាបអំពៅ ប្រកបដោយគ្រឿងយន្ត ៧ គ្រឿង ។ កុវេរព្រាហ្មណ៍បានឱ្យផលកម្រៃដល់មហាជន ដែលមហាជនមកហើយ បានផលកម្រៃធ្វើបុណ្យរៀងៗខ្លួន ។ កុវេរព្រាហ្មណ៍ ជ្រះថ្លាដោយបុណ្យនោះ បានឱ្យផលកម្រៃពីរោងគាបអំពៅទៅជាទាន អស់កាលរហូតពីរម៉ឺនឆ្នាំ បានអស់អាយុទៅកើតជាទេវបុត្រ ឈ្មោះ កុវេរៈជាស្ដេចយក្សក្នុងឋានចាតុម្មហារាជិកា ក្រោយមក ព្រះអង្គទ្រង់

បានគ្រងរាជសម្បត្តិក្នុងរាជធានីឈ្មោះ **វិសាណៈ** ទើបមាននាមថា ស្តេចវេស្សវ័ណ ។ វេស្សវ័ណមហារាជ បានសាងនគរច្រើនណាស់ ឱ្យដល់ពួកយក្សនៅឰដ៏អាកាស មានអាដានាដានគរជាដើម ។

ស្តេចវេស្សវ័ណ បានថ្វាយនូវអាដានាដិយបរិត្តដល់ព្រះ-ដ៏មានព្រះភាគ ដើម្បីព្រះដ៏មានព្រះភាគ ទ្រង់ព្រះប្រទានដល់ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា បានរៀនសូត្រ ជាប្រយោជន៍ឱ្យពួកយក្សមានសេចក្តីជ្រះថ្លា និងដើម្បីកុំឱ្យមានការបៀតបៀនពីពួកយក្ស ។

ចំណុចដែលគួរឱ្យចាប់អារម្មណ៍ គឺស្តេចវេស្សវ័ណបានក្រាបទូលព្រះដ៏មានព្រះភាគថា មានពួកយក្សជាន់ខ្ពស់ ជាន់កណ្តាល និងជាន់ទាប មិនជ្រះថ្លានឹងព្រះដ៏មានព្រះភាគក៏មានដែរ ។ យក្សដែលមិនជ្រះថ្លានឹងព្រះដ៏មានព្រះភាគ មានច្រើនណាស់ មកអំពីព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ឱ្យវៀរចាកបញ្ចវេរា ឯយក្សទាំងនោះ មិនពេញចិត្តក្នុងការវៀរចាកនូវបញ្ចវេរានោះឡើយ មានតែការប្រព្រឹត្តនូវបាណាតិបាតជាដើមដូច្នោះហើយ ទើបយក្សទាំងនោះ មិនជ្រះថ្លាក្នុងព្រះសាសនានៃព្រះពុទ្ធអង្គ ។ កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយ

កុណ្ឌីភាពហើយ ទើបស្ដេចវេស្សវណ៍ សូត្រនូវព្រះបរិត្ត ដែលមានសេចក្ដីផ្ដើម ដោយការនមស្ការព្រះពុទ្ធ ៧ ព្រះអង្គ :

វិបស្សិស្ស នមត្ថុ ចក្ខុមន្តស្ស សិរីមតោ
សិខិស្សបិ នមត្ថុ សព្វភូតានុកម្បិនោ
វេស្សភុស្ស នមត្ថុ ន្ហាតកស្ស តបស្សិនោ
នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ
កោនាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ
កស្សបស្ស នមត្ថុ វិប្បមុត្តស្ស សព្វធិ ។

អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ
យោ ឥមំ ធម្មមទេសេសិ សព្វទុក្ខា បនូទនំ ។
យេ ចាបិ និព្វុតា លោកេ យថាភូតំ វិបស្សិសុំ
តេ ជនា អបិសុណា មហន្តា វីតសារទា ។
ហិតំ ទេវមនុស្សានំ យំ នមស្សន្តិ គោតមំ
វិជ្ជាចរណសម្បន្នំ មហន្តំ វីតសារទំ ។

## សេចក្ដីប្រែ

វិបស្សិស្ស នមត្ថុ ចក្ខុមន្តស្ស សិរីមតោ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម វិបស្សី ព្រះអង្គមានចក្ខុ

ព្រះអង្គមានសិរី ។

**សិខិស្សបិ នមត្ថុ សព្វភូតានុកម្បិនោ** សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម **សិខី** ព្រះអង្គមានសេចក្ដីអនុគ្រោះ ដល់សត្វទាំងពួងជាប្រក្រតី ។

**វេស្សភុស្ស នមត្ថុ ន្ហាតកស្ស តបស្សិនោ** សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម **វេស្សភូ** ព្រះអង្គជម្រះកិលេសចេញហើយ ព្រះអង្គមាន **តបធម៌** ។

**នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ** សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម **កកុសន្ធៈ** ព្រះអង្គញាំញីនូវមារព្រមទាំងសេនានៃមារ ។

**កោនាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ** សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម **កោនាគមនៈ** ព្រះអង្គមានបាបបន្សាត់បង់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ ។

**កស្សបស្ស នមត្ថុ វិប្បមុត្តស្ស សព្វធិ** សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម **កស្សបៈ** ព្រះអង្គរួចផុតស្រឡះចាកកិលេសទាំងពួងហើយ ។

**អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ**

**យោ ឥមំ ធម្មមទេសេសិ សព្វទុក្ខា បនូទនំ ។**

សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ជាសក្យបុត្តិយ៍ ទ្រង់មានព្រះកាយផ្សាយចេញនូវព្រះរស្មី ទ្រង់មានសិរី ។ ព្រះសម្មាសម្ពុទ្ធអង្គណា ដែលសម្តែងធម៌នេះ ជាគ្រឿងបន្ទោបង់នូវសេចក្តីទុក្ខទាំងពួង ។

**យេ ចាបិ និព្វុតា លោកេ យថាភូតំ វិបស្សិសុំ**

**តេ ជនា អបិសុណា មហន្តា វីតសារទា ។**

ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលព្រះអង្គទ្រង់រំលត់កិលេសហើយ ទ្រង់ឃើញច្បាស់នូវធម៌តាមសេចក្តីពិតក្នុងលោក ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គនោះ ជាព្រះខីណាស្រព ព្រះអង្គមិនមានការញុះញង់ស៊កសៀត ទ្រង់ប្រសើរដោយគុណដ៏ធំ ប្រាសចាកសេចក្តីព្រឺស្ញើប ។

**ហិតំ ទេវមនុស្សានំ យំ នមស្សន្តិ គោតមំ**

**វិជ្ជាចរណសម្បន្នំ មហន្តំ វីតសារទំ ។**

ទេវតានិងមនុស្សទាំងឡាយ តែងនមស្ការព្រះសម្មាសម្ពុទ្ធអង្គឯណា ជាគោតមគោត្រ ព្រះសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ញុំាងនូវប្រយោជន៍ឱ្យដល់ទេវតានិងមនុស្សទាំងឡាយ ទ្រង់បរិបូណ៌

ដោយវិជ្ជានិងចរណៈ ទ្រង់ប្រសើរដោយគុណដ៏ធំ ប្រាសចាកសេចក្តីព្រឺស្ញើប ។

នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ **ចូររៀន**នូវព្រះបរិត្តសម្រាប់រក្សាក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរទន្ទេញឱ្យចាំស្ទាត់នូវព្រះបរិត្តសម្រាប់រក្សា ក្នុងអាដា-នាដានគរ ម្នាលភិក្ខុទាំងឡាយ ការរក្សាក្នុងអាដានាដានគរនេះ ប្រកបដោយប្រយោជន៍ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅជាសុខ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។

លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុទាំងនោះ មានចិត្តត្រេកអរទទួលអនុមោទនានឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ដោយប្រការដូច្នេះឯង ។

**សូមអនុមោទនា !**

## លោកនៃការរស់នៅ

លោកនៃការរស់នៅ គឺជាអារម្មណ៍របស់ចិត្តនិងចេតសិក។

រូបារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈឃើញ សទ្ទា-រម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈឮ គន្ធារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈធុំក្លិន រសារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈដឹងរស ផោដ្ឋព្វារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈដឹងផោដ្ឋព្វៈ ធម្មារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈនៃការដឹងធម្មារម្មណ៍ហ្នឹងឯង ។

កាលបើលោកនៃការរស់នៅ គឺជាអារម្មណ៍របស់ចិត្តនិងចេតសិក ដូច្នេះអ្វីដែលរស់នៅក្នុងលោក គឺគ្មានអ្វីក្រៅអំពីចិត្តនិងចេតសិកនោះឡើយ ។

រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ប្រាកដជាអារម្មណ៍នៃរូបកម្មដ្ឋាន ចំណែកនាមធម៌ដែលដឹងនូវអារម្មណ៍នោះ ប្រាកដជាអារម្មណ៍នៃអរូបកម្មដ្ឋាន ។ រូបកម្មដ្ឋាន និងអរូបកម្មដ្ឋាននេះឯងជាវិបស្សនា ។ វិបស្សនាកំណត់ដឹងរូបធម៌ នាមធម៌ តាមទ្វារទាំង ៦ លះបង់នូវអត្តសញ្ញា ព្រមទាំងវិចិកិច្ឆាក្នុងបដិបត្តិធម៌ ។

# ៤. សង្គីតិសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅអម្ពវ័នរបស់នាយចុន្ទ-កម្មារបុត្រ ជិតក្រុងបាវា មួយអន្លើដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ភិក្ខុសង្ឃទាំង ៥០០ អង្គនេះ បានចូលក្នុងសំណាញ់ព្រះញាណនៃព្រះពុទ្ធអង្គ គឺព្រោះបានស្តាប់នូវសង្គីតិសូត្រ ដែលព្រះសារីបុត្តនឹងសម្តែងនៅនគរបាវាហើយ នឹងបានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ដូច្នេះហើយទើបព្រះអង្គទ្រង់ស្តេចយាងទៅកាន់នគរបាវា ដើម្បីបានជាហេតុនៃការសម្តែងសង្គីតិសូត្រហ្នឹងឯង ។

ហេតុដែលព្រះសារីបុត្ត សម្តែងសង្គីតិសូត្រ ព្រោះនិគ្គណ្ឋនាដបុត្ត ទើបតែធ្វើមរណកាលថ្មីៗក្នុងក្រុងបាវា ក្នុងកាលនោះ សិស្សរបស់និគ្គណ្ឋនាដបុត្ត ឈ្លោះទាស់ទែងបែកបាក់គ្នានេះមកពី ធម្មវិន័យដែលនិគ្គណ្ឋនាដបុត្ត ពោលទុកដោយអាក្រក់ហើយ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រំងាប់ មិនមែនជាធម្មវិន័យដែលព្រះសម្មាសម្ពុទ្ធសម្តែងទុកយ៉ាងនេះឯង ។

ព្រះសារីបុត្តបានសម្តែងយ៉ាងពីរោះថា ម្នាលអាវុសោ

ទាំងឡាយ ធម៌នេះឯង ព្រះដ៏មានព្រះភាគនៃយើងទាំងឡាយ បានសម្តែងទុកល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិក-ធម៌ ប្រព្រឹត្តទៅដើម្បីស្ងប់រំងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធសម្តែងទុកហើយ គួរតែយើងទាំងអស់គ្នាសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះ ឋិតថេរតាំងនៅអស់កាលជាយូរអង្វែងដោយហេតុណា ហេតុនោះឯងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

នៅក្នុងព្រះសូត្រនេះ ព្រះសារីបុត្តសម្តែងធម៌ ១០ ពួក គឺតាំងពីពួកមួយដល់ពួកដប់ ។ ធម៌ពួកមួយមាន ២, ធម៌ពួកពីរមាន ៣៥ ទុកៈ, ធម៌ពួកបីមាន ៦០ តិកៈ, ធម៌ពួកបួនមាន ៥០ ចតុកៈ, ធម៌ពួកប្រាំមាន ២៦ បញ្ចកៈ, ធម៌ពួកប្រាំមួយមាន ២២ ឆកៈ, ធម៌ពួកប្រាំពីរមាន ១៤ សត្តកៈ, ធម៌ពួកប្រាំបីមាន ១១ អដ្ឋកៈ, ធម៌ពួកប្រាំបួនមាន ៦ នវកៈ និងធម៌ពួកដប់មាន ៦ ទសកៈ ។

សរុបធម៌ដែលព្រះសារីបុត្តសម្តែងទាំងអស់មាន ១០១៤ ធម៌ ។ ព្រះសូត្រដទៃក្នុងព្រះពុទ្ធវចនៈ មិនមានព្រះសូត្រណាដែលមានធម៌ច្រើនយ៉ាងនេះឡើយ ព្រះដ៏មានព្រះភាគ ទ្រង់ពេញ

ព្រះហឫទ័យ ព្រះអង្គទ្រង់ប្រទានសាធុកាថា ម្នាលសារីបុត្ត ល្អហើយ ល្អហើយ ម្នាលសារីបុត្ត អ្នកបានសម្តែងនូវសង្គីតិបរិយាយដល់ភិក្ខុទាំងឡាយ ជាការប្រពៃពេកណាស់ ។

**សូមអនុមោទនា !**

## សត្វទាំងឡាយឋិតនៅបានដោយអាហារ

សត្វទាំងអស់ សុទ្ធតែរស់នៅបានដោយសារអាហារ សូម្បីអសញ្ញីព្រហ្ម មានជីវិតតាំងនៅបាន ក៏ដោយសារមានឈានជាអាហារហ្នឹងឯង ។

**អាហារដោយត្រង់** មានបួនគឺ កវឡិង្ការាហារ ១, ផស្សាហារ ១, មនោសញ្ចេតនាហារ ១ និងវិញ្ញាណាហារ ១ ។

កវឡិង្ការាហារ នាំមកនូវអាហារជរូប និងឧបត្ថម្ភដល់រូបផ្សេងទៀត មានកម្មជរូបជាដើម ។

ផស្សាហារ នាំមកនូវវេទនាបី ។ មនោសញ្ចេតនាហារ នាំមកនូវភពថ្មី ។ វិញ្ញាណាហារ នាំមកនូវនាមរូប ។

**អាហារដោយអម** សំដៅយកបច្ច័យផ្សេងៗទៀតក្រៅអំពីអាហារប្បច្ច័យ ដូចជានីវរណធម៌ ៥ ជាអាហារនៃអវិជ្ជា ឬអយោ-

និសោមនសិការជាអាហារនៃនីវរណធម៌ ៥ ជាដើម ឬក៏ផ្នែកខាងល្អវិញដូចជា ការសេពគប់សប្បុរស ជាអាហារនៃការស្តាប់ធម៌, ការស្តាប់ធម៌ជាអាហារនៃសទ្ធា, សទ្ធាជាអាហារនៃយោនិសោមនសិការ រហូតដល់សតិប្បដ្ឋាន ៤ ជាអាហារនៃពោជ្ឈង្គ ៧, ពោជ្ឈង្គ ៧ ជាអាហារនៃវិជ្ជានិងវិមុត្តិ ដូច្នេះជាដើម ។

ពាក្យថា សត្វទាំងអស់ គឺធម៌ទាំងពួងហ្នឹងឯង ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះថា ដោយបរមត្ថ មិនមានសត្វអ្នកបរិភោគនូវអាហារនោះឡើយ មានតែរូបធម៌និងនាមធម៌ដែលអាស្រ័យបច្ច័យកើតឡើង ហើយវិនាសទៅវិញតែប៉ុណ្ណោះ ។

# ៥. ទសុត្តរសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ជិតក្រុងចម្ប៉ា ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន ៥០០ អង្គ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបឧបនិស្ស័យនៃភិក្ខុទាំងអស់នោះ ដែលព្រះសារីបុត្តគួរគប្បីណែនាំ ទើបទ្រង់បញ្ជូនឱ្យទៅកាន់សម្នាក់ព្រះសារីបុត្ត ។ ក្នុងកាលនោះ ព្រះសារីបុត្តបានពិចារណាឃើញធម៌ជាពួកៗ សមនឹងអធ្យាស្រ័យនៃភិក្ខុទាំងឡាយនោះ ដែលត្រេកអរក្នុងការព្រមព្រៀងគ្នា ។ មុននឹងសម្តែង ព្រះសារី-បុត្តបានប្រកាសធម៌មួយគាថា ដើម្បីញ៉ាំងសេចក្តីស្រឡាញ់ក្នុងព្រះធម៌ទេសនានោះ ឱ្យកើតឡើងដល់ពួកភិក្ខុ ឱ្យពួកភិក្ខុមានសេចក្តីសម្គាល់ក្នុងទសុត្តរសូត្រនោះថា ជាធម៌ដែលខ្លួនគប្បីរៀនគប្បីសិក្សា គប្បីទ្រទ្រង់ចាំទុក គប្បីប្រាប់ ដោយប្រការដូច្នេះរបៀបដូចដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងផ្តើមក្នុងមហាសតិប្បដ្ឋានសូត្រថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ** ដូច្នេះជាដើម ។

មួយគាថា ដែលព្រះសារីបុត្តដ៏មានអាយុ បានសម្តែងយ៉ាងនេះថា

**ទសុត្តរំ បវក្ខាមិ ធម្មំ និព្វានបត្តិយា**

**ទុក្ខស្សន្តកិរិយាយ សព្វគន្ថប្បមោចនន្តិ ។**

ខ្ញុំនឹងសម្តែងនូវទសុត្តរធម៌ ជាធម៌សម្រាប់ដោះស្រាយនូវគ្រឿងចាក់ស្រែះ គឺកិលេសទាំងអស់ ដើម្បីបានដល់ព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃវដ្តទុក្ខ ។

នៅក្នុងទសុត្តរសូត្រនេះ មានធម៌ ៥៥០ ដោយរាប់តាមមាតិកាធម៌មួយ មានធម៌ ៥៥ រហូតគ្រប់មាតិកាធម៌ទាំងដប់ ។

## មាតិកាធម៌ ១០

១- **ពហុការធម៌** ធម៌មានឧបការៈច្រើន

២- **ភាវេតព្វធម៌** ធម៌គួរចម្រើន

៣- **បរិញ្ញេយ្យធម៌** ធម៌គួរកំណត់ដឹង

៤- **បហាតព្វធម៌** ធម៌គួរលះបង់

៥- **ហានភាគិយធម៌** ធម៌ជាចំណែកនៃសេចក្តីវិនាស

៦- **វិសេសភាគិយធម៌** ធម៌ជាចំណែកវិសេស

៧- **ទុប្បដិវិជ្ឈធម៌** ធម៌ត្រាស់ដឹងបានដោយក្រ

៨- **ឧប្បាទេតព្វធម៌** ធម៌គួរឱ្យកើតឡើង

៩- **អភិញ្ញេយ្យធម៌** ធម៌គួរដឹងច្បាស់

១០- **សច្ឆិកាតព្វធម៌** ធម៌គួរធ្វើឱ្យជាក់ច្បាស់ ។

នៅក្នុងមាតិកាធម៌មួយៗ មានធម៌ ៥៥ ស្មើៗគ្នា គឺបូកពីពួកមួយដល់ពួកដប់

## ១. ពហុការធម៌ ១០ ពួក

១- មិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ។

២- សតិ ១, សម្បជញ្ញៈ ១ ។

៣- សេពគប់សប្បុរស ១, ស្តាប់ធម៌សប្បុរស ១, ប្រតិបត្តិធម៌សមគួរដល់ធម៌ ១ ។

៤- ចក្កធម៌ ៤ យ៉ាង ។

៥- បធានិយង្គ អង្គដែលជាទីតាំងនៃវីរិយៈ ៥ ប្រការ ។

៦- សារាណីយធម៌ ៦ ប្រការ ។

៧- អរិយទ្រព្យ ៧ ។

៨- ហេតុ ៨ ប្រការ, បច្ច័យ ៨ ប្រការ រមែងប្រព្រឹត្តទៅដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនទាន់បាន ដើម្បីធ្វើនូវបញ្ញាដែលខ្លួនបានស៊ប់ហើយ ឱ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។

៩- ធម៌ដែលមានយោនិសោមនសិការជាឫសគល់ ៩ ។

១០- នាថករណធម៌ ១០ ។

## ២. ភាវេតព្វធម៌ ១០ ពួក

១- កាយគតាសតិ សាតសហគតា ។

២- សមថៈ ១, វិបស្សនា ១ ។

៣- សមាធិ ៣ យ៉ាង ។

៤- សតិប្បដ្ឋាន ៤ ។

៥- សម្មាសមាធិប្រកបដោយអង្គ ៥ ។

៦- អនុស្សតិដ្ឋាន ៦ យ៉ាង ។

៧- សម្ពោជ្ឈង្គ ៧ ។

៨- អរិយមគ្គ ប្រកបដោយអង្គ ៨ ។

៩- អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ៩ យ៉ាង។

១០- កសិណាយតនៈ ១០ យ៉ាង ។

## ៣. បរិញ្ញេយ្យធម៌ ១០ ពួក

១- ផស្សៈដែលប្រកបដោយអាសវៈជាទីតាំងនៃឧបាទាន។

២- នាម ១, រូប ១ ។

៣- វេទនា ៣ ប្រការ ។

៤- អាហារ ៤ ។

៥- ឧបាទានក្ខន្ធ ៥ ។

៦- អាយតនៈខាងក្នុង ៦ ។

៧- វិញ្ញាណដ្ឋិតិ ៧ ។

៨- លោកធម៌ ៨ ប្រការ ។

៩- សត្តាវាស ៩ ។

១០- អាយតនៈ ១០ ។

## ៤_ បហាតព្វធម៌ ១០ ពួក

១- អស្មិមានះ ។

២- អវិជ្ជា ១, ភវតណ្ហា ១ ។

៣- តណ្ហា ៣ ប្រការ ។

៤- អន្ធង់ ៤ ។

៥- នីវរណធម៌ ៥ ។

៦- តណ្ហា ៦ ។

៧- អនុស័យ ៧ ។

៨- មិច្ឆត្តៈ ៨ ។

៩- ធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង (តណ្ហា-

មូលិកា ធម្មា ) ។

១០- មិច្ឆត្តៈ ១០ ។

## ៥_ ហានភាគិយធម៌ ១០ ពួក

១- អយោនិសោមនសិការ ។

២- ទោវចស្សតា ១, បាបមិត្តតា ១ ។

៣- អកុសលមូល ៣ យ៉ាង ។

៤- យោគៈ ៤ ។

៥- ចេតោខិលៈ ៥ ។

៦- អគារវៈ ៦ ។

៧- អសទ្ធម្ម ៧ ។

៨- កុសីតវត្ថុ ៨ ។

៩- អាឃាតវត្ថុ ៩ ។

១០- អកុសលកម្មបថ ១០ ។

## ៦_ វិសេសភាគិយធម៌ ១០ ពួក

១- យោនិសោមនសិការ ។

២- សោវចស្សតា ១, កល្យាណមិត្តតា ១ ។

៣- កុសលមូល ៣ យ៉ាង ។

៤- វិសំយោគៈ ៤ ។

៥- ឥន្ទ្រិយ ៥ ។

៦- គារវៈ ៦ ។

៧- ព្រះសទ្ធម្ម ៧ ។

៨- អារព្ភវត្ថុ ៨ ។

៩- អាឃាតប្បដិវិន័យ ៩ ។

១០- កុសលកម្មបថ ១០ ។

## ៧. ទុប្បដិវិជ្ឈធម៌ ១០ ពួក

១- អនន្តរិកចេតោសមាធិ (សមាធិ ក្នុងអរិយមគ្គ ដែលជាលំដាប់នៃវិបស្សនា) ។

២- ហេតុនិងបច្ច័យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសៅហ្មង របស់សត្វទាំងឡាយ ១ , ហេតុនិងបច្ច័យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ របស់សត្វទាំងឡាយ ១ ។

៣- និស្សារណីយធាតុ (ធាតុដែលជាទីតាំងនៃការរលាស់ចេញ) ៣ ប្រការ ។

៤- សមាធិ ៤ (ជាចំណែកនៃសេចក្តីវិនាសព្រោះកាម ១, ជាចំណែកនៃការតាំងមាំព្រោះសតិ ១ , ជាចំណែកនៃសេចក្តី

វិសេសព្រោះអភិញ្ញា ១, ជាចំណែកនៃការចាក់ធ្លុះ ទម្លាយកិលេស ព្រោះវិបស្សនា ១ ) ។

៥- និស្សារណីយធាតុ ៥ ។

៦- និស្សារណីយធាតុ ៦ ។

៧- សប្បុរិសធម៌ ៧ ។

៨- អក្ខណៈ អសម័យ ៨ យ៉ាង (ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចរិយធម៌ ) ។

៩- នានត្តៈ គឺធម៌ផ្សេងៗ ៩ យ៉ាង ។

១០- អរិយវាសៈ គឺធម៌ជាគ្រឿងនៅអាស្រ័យរបស់ព្រះ-អរិយៈ ១០ យ៉ាង ។

## ៨~ ឧប្បាទេតព្វធម៌ ១០ ពួក

១- ញាណដែលមិនកម្រើក គឺ បច្ចវេក្ខណញ្ញាណ ។

២- ញាណដឹងក្នុងការអស់ទៅ ១, ញាណដឹងក្នុងការមិនកើតឡើង ១ ។

៣- ញាណដឹងចំណែកអតីត ១ , ញាណដឹងចំណែកអនាគត ១, ញាណដឹងចំណែកបច្ចុប្បន្ន ១ ។

៤- ញាណដឹងក្នុងធម៌ ១ , ញាណដឹងក្នុងការយល់តាម

(អនុមាន ) ១, ញាណដឹងក្នុងការកំណត់ ១, ញាណដឹងក្នុងសម្មតិ ១ ។

៥- សម្មាសមាធិ ប្រកបដោយញាណ ៥ ។

៦- សតតវិហារធម៌ (ធម៌ជាគ្រឿងនៅមិនដាច់នៃព្រះខីណាស្រព បានដល់ឆឡង្គុបេក្ខា) ។

៧- សញ្ញា ៧ ប្រការ មានអនិច្ចសញ្ញាជាដើម ។

៨- មហាបុរិសវិតក្ក ៨ ប្រការ មានសេចក្តីត្រិះរិះថា ធម៌នេះគឺលោកុត្តរធម៌ ៩ រមែងសម្រេចដល់បុគ្គលដែលមានសេចក្តីប្រាថ្នាតិច មិនមែនជាធម៌របស់បុគ្គលដែលមានសេចក្តីប្រាថ្នាច្រើនឡើយ ជាដើម ។

៩- សញ្ញា ៩ ប្រការ មានអសុភសញ្ញាជាដើម ។

១០- សញ្ញា ១០ ប្រការ មាននិរោធសញ្ញាជាគម្រប់ ១០ ។

## ៩. អភិញ្ញេយ្យធម៌ ១០ ពួក

១- សព្វេ សត្តា អាហារដ្ឋិតិកា ។

២- សង្ខតធាតុ ១, អសង្ខតធាតុ ១ ។

៣- កាមធាតុ ១, រូបធាតុ ១, អរូបធាតុ ១ ។

៤- អរិយសច្ច ៤ ។

៥- វិមុត្តាយតនៈ ៥ ។

៦- អនុត្តរិយធម៌ ៦ មានទស្សនានុត្តរិយៈជាដើម ។

៧- និទ្ទសវត្ថុ ៧ (ធម៌ដែលឱ្យបានជាព្រះខីណាស្រព បរិនិព្វានទៅ មិនមានបដិសន្ធិ ១០ ឆ្នាំ ឬសូម្បីតែមួយខណៈក៏មិនមានដែរ) ។

៨- អភិភាយតនៈ ៨ យ៉ាង (ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអារម្មណ៍ផង) ។

៩- អនុបុព្វវិហារធម៌ ៩ យ៉ាង (ធម៌ជាគ្រឿងសម្រេចសម្រាន្តនៅជាសុខ តាមលំដាប់) ។

១០- និជ្ជិណ្ណវត្ថុ ១០ យ៉ាង (សម្មត្តៈ ១០ ធ្វើឱ្យមិច្ឆត្តៈ ១០ សាបសូន្យអស់) ។

## ១០~ សច្ឆិកាតព្វធម៌ ១០ ពួក

១- អកុប្បាចេតោវិមុត្តិ (ការរួចផុតនៃចិត្តដោយមិនកម្រើក) ។

២- វិជ្ជា ១, វិមុត្តិ ១ ។

៣- វិជ្ជា ៣ ។

៤- សាមញ្ញផល ៤ ។

៥- ធម្មក្ខន្ធ ៥ (មានសីលក្ខន្ធជាដើម) ។

៦- អភិញ្ញា ៦ ។

៧- ខីណាសវពលានិ (កម្លាំងនៃព្រះខីណាស្រព) ៧ ។

៨- វិមោក្ខ ៨ ប្រការ ។

៩- អនុបុព្វនិរោធ ៩ យ៉ាង ។

១០- អសេក្ខធម៌ ១០ ។

ភិក្ខុ ៥០០ អង្គបានស្តាប់ទសុត្តរសូត្រនេះហើយ ពិចារណាសេចក្តីនៃព្រះសូត្រ ក៏តាំងនៅក្នុងព្រះអរហត្តផល ព្រមទាំងបដិសម្ភិទាទាំងឡាយ ក៏ព្រោះមានចិត្តរីករាយក្នុងការស្តាប់ព្រះធម៌ហ្នឹងឯង ។

**សូមអនុមោទនា !**

## ខ្លឹមសារក្នុងមាតិកា ១០

១- **ពហុការោ** មានឧបការៈច្រើន ។

២- **ភាវេតព្វោ** គួរឱ្យចម្រើន ។

៣- **បរិញ្ញេយ្យោ** គួរកំណត់ដឹងដោយបរិញ្ញា ៣ ។

៤- **បហាតព្វោ** គួរលះដោយបហានានុបស្សនា ។

៥- **ហានភាគិយោ** មានប្រក្រតីឱ្យទៅកាន់អបាយ ប្រព្រឹត្ត ទៅព្រមដើម្បីសេចក្ដីវិនាសដោយជុំវិញ ។

៦- **វិសេសភាគិយោ** មានប្រក្រតីឱ្យដល់នូវគុណវិសេស ប្រព្រឹត្តទៅព្រមដើម្បីសេចក្ដីវិសេស ។

៧- **ទុប្បដិវិជ្ឈោ** ធ្វើឱ្យប្រចក្សបានដោយលំបាក ។

៨- **ឧប្បាទេតព្វោ** គួរឱ្យសម្រេច ។

៩- **អភិញ្ញេយ្យោ** គួរដឹងច្បាស់ដោយញាតបរិញ្ញា ។

១០- **សច្ឆិកាតព្វោ** គួរធ្វើឱ្យប្រចក្ស ។

ក្នុងមាតិកាទាំងដប់ បណ្ឌិតគប្បីជ្រាបសេចក្ដី ដោយប្រការ ដូច្នេះ ។

# **ទីឃនិកាយ ៣៤ សូត្រ**

១- **ព្រហ្មជាលសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងសួនឈ្មោះ **អម្ពលដ្ឋិកា** នៅរវាងក្រុងរាជគ្រឹះនិងនាឡន្ទគ្រាមព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធសុប្បិយ-បរិព្វាជក ពោលតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងព្រហ្ម-ទត្តមាណពជាកូនសិស្សរបស់សុប្បិយបរិព្វាជក ពោលសរសើរគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

**ខ្លឹមសារ** ទិដ្ឋិ ៦២ ។

២- **សាមញ្ញផលសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ**ជីវកម្ពវ័ន** រវាងក្រុងរាជគ្រឹះនិងភ្នំគិជ្ឈកូដ ព្រមដោយភិក្ខុសង្ឃ ១២៥០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធព្រះបាទអជាតសត្តុវេទេហីបុត្រដែលបានទូលសួរអំពីផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

**ខ្លឹមសារ** សីល សមាធិ បញ្ញា ។

៣- **អម្ពដ្ឋសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងស្រុក

ព្រាហ្មណ៍ នាដងព្រៃឈ្មោះ **ឥច្ឆានង្គលៈ** ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធអម្ពដ្ឋមាណព ជាសិស្សរបស់បោក្ខរសាតិព្រាហ្មណ៍ ត្រាស់សម្តែងអំពីវិជ្ជានិង ចរណៈ ។ រំលងមួយរាត្រី ព្រះដ៏មានព្រះភាគទ្រង់ប្រោសបោក្ខរ-សាតិព្រាហ្មណ៍ ឱ្យតាំងនៅក្នុងសោតាបត្តិផល ។

**ខ្លឹមសារ** បុគ្គលដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ ជាមនុស្សប្រសើរបំផុត ក្នុងពួកទេវតានិងមនុស្សទាំងឡាយ ។

៤- **សោណទណ្ឌសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅជិតក្រុងចម្ប៉ា ទៀបឆ្នេរនៃស្រះបោក្ខរណី ឈ្មោះ **គគ្គរា** ក្នុងអង្គជនបទ ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធសោណទណ្ឌព្រាហ្មណ៍ ត្រាស់សួរអំពីមនុស្សប្រកបដោយអង្គប៉ុន្មាន ដែលពួកព្រាហ្មណ៍បញ្ញត្តថាជាព្រាហ្មណ៍ ។

**ខ្លឹមសារ** **បញ្ញា**ជម្រះ**សីល** ឱ្យបរិសុទ្ធ ឯ**សីល**សោតក៏ជម្រះ**បញ្ញា** ឱ្យបរិសុទ្ធដែរ ។

៥- **កូដទន្តសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅស្រុកព្រាហ្មណ៍ឈ្មោះ **ខានុមត្តៈ** នាសួនអម្ពលដ្ឋិកា ក្នុងមគធជនបទ

ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធកូដទន្ត-ព្រាហ្មណ៍ ដែលរៀបចំសម្លាប់សត្វដ៏ច្រើនក្នុងពិធីបូជាយញ្ញ ហើយបានចូលមកទូលសួរព្រះអង្គអំពីយញ្ញសម្បទា ៣ ប្រការ មានបរិក្ខា ១៦ ទាំងបានទូលសួរតៗអំពីយញ្ញដទៃដែលមានផល ច្រើន មានអានិសង្សច្រើនឡើងទៀត ។ កូដទន្តព្រាហ្មណ៍ បាន ចាត់ចែងឱ្យដោះលែងសត្វ ដែលបានរៀបចំបូជាយញ្ញទាំងនោះ រួចហើយបានស្តាប់ព្រះធម៌បន្ត តាំងនៅក្នុងសោតាបត្តិផល ។

**ខ្លឹមសារ** យញ្ញក្នុងព្រះពុទ្ធសាសនា គឺជាការលះបង់នូវ កិលេសតាមលំដាប់ ។

៦- **មហាលិសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង **កូដាគារសាលា** នាមហាវ័ន ជិតក្រុងវេសាលី ។ ព្រះអង្គទ្រង់ ប្រារព្ធមហាលិ ដែលជាក្សត្រិយ៍លិច្ឆវីមួយអង្គ ចូលមកទូលសួរ ព្រះអង្គ ទាក់ទងនឹងរឿងរ៉ាវសុនក្ខត្តលិច្ឆវិបុត្រ បានទិព្វចក្ខុ តែ មិនបាននូវទិព្វសោត ។

**ខ្លឹមសារ** ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះតថាគត ចម្រើនអរិយមគ្គអង្គ ៨ ។

៧- **ជាលិយសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង **ឃោសិតារាម** ជិតក្រុងកោសម្ពី ។ ព្រះអង្គទ្រង់ប្រារព្ធមណ្ឌិយ-បរិព្វាជក និងជាលិយៈ ជាសិស្សរបស់ទារុបត្តិកបរិព្វាជក ដែលមកទូលសួរព្រះអង្គថា ជីវៈនោះគឺសរីរៈនោះ ឬជីវៈដទៃ ឯសរីរៈដទៃផ្សេងទៀត ។

**ខ្លឹមសារ** ដូចសាមញ្ញផលសូត្រដែរ ។

៨- **មហាសីហនាទសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឈ្មោះ **កណ្ណកថលៈ** ជាទីឱ្យអភ័យដល់ម្រឹគ ជិតក្រុងឧជុញ្ញា ។ ព្រះអង្គទ្រង់ប្រារព្ធអចេលកស្សបៈ ដែលទូលសួរព្រះអង្គអំពី **តបធម៌** (តបៈ) ។

**ខ្លឹមសារ** សីលសម្បទា ចិត្តសម្បទា និងបញ្ញាសម្បទា ព្រមទាំងមហាសីហនាទ ១១០ ។

៩- **បោដ្ឋបាទសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង **វត្តជេតពន** ជិតក្រុងសាវត្ថី ។ ព្រះអង្គទ្រង់ស្តេចយាងចូលទៅកាន់មល្លិការាម ជួបនឹងបោដ្ឋបាទបរិព្វាជក បោដ្ឋបាទបានទូលសួរព្រះអង្គអំពីអភិសញ្ញានិរោធ ។

**ខ្លឹមសារ** ការលះបង់នូវអត្តភាពទាំង ៣ គឺឱឡារិកអត្តភាព ១, មនោមយអត្តភាព ១, និងអរូបអត្តភាព ១ ។

១០- **សុភសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វានទៅហើយ បានជាង ១ ខែ កាលនោះ ព្រះអានន្ទត្ថេរគង់នៅក្នុង **វត្តជេតពន** ជិតក្រុងសាវត្ថី ។ សុភមាណពកូនតោទេយ្យ-ព្រាហ្មណ៍ បាននិមន្តព្រះអានន្ទត្ថេរ មកគេហដ្ឋានរបស់ខ្លួន ហើយបានអារាធនាព្រះអានន្ទ សូមឱ្យព្រះអានន្ទត្ថេរប្រកាសសម្តែងធម៌ដែលព្រះដ៏មានព្រះភាគតែងសរសើរនូវធម៌ទាំងឡាយណា និងបានណែនាំប្រជុំជនឱ្យតាំងនៅ ឱ្យប្រតិស្ឋានក្នុងធម៌ទាំងឡាយណា ធម៌ទាំងឡាយនោះ ដូចម្តេច ។

**ខ្លឹមសារ** អរិយសីលក្ខន្ធ ១, អរិយសមាធិក្ខន្ធ ១, អរិយ-បញ្ញាខន្ធ ១ ។

១១- **កេវដ្ឋសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **បាវារិកម្ពវ័ន** ជិតស្រុកនាឡន្ទា ។ ព្រះអង្គទ្រង់ប្រារព្ធកេវដ្ឋ-គហបតិបុត្រ ដែលចូលមកសូមពរព្រះអង្គ សូមឱ្យព្រះដ៏មាន-ព្រះភាគត្រាស់បង្គាប់ភិក្ខុ ១ អង្គ ឱ្យភិក្ខុនោះធ្វើបាដិហារ្យសម្តែង

ឫទ្ធិ ដើម្បីអ្នកស្រុកនាឡន្ទានេះ រឹងរឹតតែជ្រះថ្លាឡើងក្នុងព្រះដ៏-មានព្រះភាគ ។

**ខ្លឹមសារ** បាដិហារ្យ ៣ យ៉ាង ។ អនុសាសនីបាដិហារ្យ ប្រសើរបំផុត ព្រោះឱ្យដល់នូវលោកុត្តរធម៌ ។

១២- **លោហិច្ចសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅស្រុកមួយឈ្មោះ **សាលវតិកា** ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធលោហិច្ចព្រាហ្មណ៍ជាម្ចាស់ស្រុក មានទិដ្ឋិអាក្រក់កើតឡើង បដិសេធការសង្គ្រោះ ។

**ខ្លឹមសារ** សាស្តា ៣ ពួក ដែលគួរដល់ការចោទប្រកាន់ ដោយឡែកពីព្រះសម្មាសម្ពុទ្ធ ។

១៣- **តេវិជ្ជសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅស្រុកព្រាហ្មណ៍ឈ្មោះ **មនសាកតៈ** នៅក្រោមដើមស្វាយ មាត់ស្ទឹងអចិរវតី ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធ វាសេដ្ឋមាណព និងភារទ្វាជមាណព ដែលបានក្រាបទូលព្រះអង្គអំពីការបញ្ញត្តផ្លូវទាំងឡាយផ្សេងៗគ្នា របស់ពួកព្រាហ្មណ៍ថា ផ្លូវទាំងនោះសុទ្ធតែស្រោចស្រង់សត្វ នាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឱ្យទៅកើតជាមួយនឹងពួកព្រហ្មបាន ។

**ខ្លឹមសារ** ពួកព្រាហ្មណ៍ដែលបានត្រៃវិជ្ជា ។

១៤- **មហាបទានសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **វត្តជេតពន** ព្រះអង្គសម្តែងធម្មីកថា ប្រកបដោយបុព្វេនិវាស ។

**ខ្លឹមសារ** ព្រះសម្មាសម្ពុទ្ធ ៧ អង្គ ។

១៥- **មហានិទានសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **កម្មាសទម្មនិគម** ក្នុងកុរុជនបទ ។ ព្រះអង្គទ្រង់ប្រារព្ធព្រះអានន្ទ ហើយសម្តែងព្រះធម៌ អំពី បដិច្ចសមុប្បាទធម៌ ។

**ខ្លឹមសារ** បដិច្ចសមុប្បាទធម៌ ។

១៦- **មហាបរិនិព្វានសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើ **ភ្នំគិជ្ឈកូដ** រហូតដល់ **កុសិនារា** ។ ព្រះអង្គប្រារព្ធការបរិនិព្វានរបស់ព្រះអង្គ ។ ទ្រង់ញ៉ាំងបរិស័ទឱ្យសង្វេគ ប្រឹងប្រែងក្នុងកិច្ចរបស់ខ្លួន ។

**ខ្លឹមសារ** អប្បមាទធម៌ ។

១៧- **មហាសុទស្សនសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **កុសិនារា** ទ្រង់សម្រេចសីហសេយ្យាដោយអនុដ្ឋានសញ្ញា

ក្នុងឧទ្យានសាលវ័ន ។ ព្រះអង្គទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ដែលក្រាបទូលសូមកុំឱ្យព្រះអង្គបរិនិព្វានក្នុងនគរកុសិនារានេះ ព្រោះជានគរតូច ។

**ខ្លឹមសារ** គួរបំពេញកុសល ឱ្យបានដល់ទីបំផុតទុក្ខ សង្ខារទាំងឡាយ មានហើយរកមានមិនបាន ។

១៨- **ជនវសភសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងលំនៅដែលធ្វើដោយឥដ្ឋ ជិត **នាតិកគ្រាម** ក្នុងព្រះដំណើរស្តេច យាងទៅគង់ចាំព្រះវស្សាទី ៤៥ នៅវេឡុវគ្រាម ជិតក្រុងវេសាលី ។ ព្រះអង្គទ្រង់ប្រារព្ធជនវសភយក្ស ដែលមានអតីតជាតិគឺព្រះបាទពិម្ពិសារ ចូលគាល់ព្រះអង្គនិងក្រាបទូលអំពីអង្គប្រជុំនៅទេវលោក ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករនូវគតិនៃពួកជនដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

**ខ្លឹមសារ** សាសនព្រហ្មចរិយធម៌ ដល់នូវសេចក្តីចម្រើនមាំមួន ផ្សាយទៅសព្វទិស ដោយសារការប្រកាសសម្តែង ។ (សនង្កុមារព្រហ្មប្រកាសសម្តែងនៅស្ថានតាវត្តិង្ស ស្តេចវេស្សវណ្ណនាំយកមកប្រកាសនៅស្រុកយក្ស ជនវសភយក្សក៏បានក្រាបទូលព្រះដ៏មានព្រះភាគ បន្តមកដល់ព្រះអានន្ទ ភិក្ខុ ភិក្ខុនី ឧបាសក

ឧបាសិកា ) ។

១៩- **មហាគោវិន្ទសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **ភ្នំគិជ្ឈកូដ** ជិតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ប្រារព្ធបញ្ចសិខគន្ធព្វ-បុត្រ ចូលមកគាល់ព្រះអង្គ ក្រាបទូលអំពីមហាគោវិន្ទចរិយា ដែលសនង្កុមារព្រហ្មបានសម្តែងប្រាប់នៅទេវលោក ស្ថានតាវត្តិង្ស។

**ខ្លឹមសារ** ទានបារមីនៃព្រះបរមពោធិសត្វ មហាគោវិន្ទ-ព្រាហ្មណ៍ ។

២០- **មហាសមយសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **មហាវ័ន** ជិតក្រុងកបិលវត្ថុ ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ សុទ្ធតែព្រះអរហន្តទាំងអស់ ។ ព្រះអង្គទ្រង់ប្រារព្ធពួកទេវតានិងព្រហ្មដែលមានភ័ព្វ ចែកជា ៦ ពួកដោយអំណាចនៃចរិត ប្រកាសសម្តែងព្រះធម៌ក្នុងមហាសម័យនោះឯង ។

**ខ្លឹមសារ** មហាប្រជុំទេវតានិងព្រហ្ម មានការជុំគ្នាច្រើនប្រយោជន៍ដើម្បីឃើញព្រះដ៏មានព្រះភាគ ហើយបានស្តាប់ព្រះធម៌នាំមកនូវសេចក្តីសុខ ។

២១- **សក្កបញ្ហសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង

**ឥន្ទសាលគុហា** ជិតភ្នំវេទិយកៈ ខាងកើតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ប្រារព្ធសក្កទេវរាជ ដែលយាងចុះមកក្រាបទូលសួរបញ្ហាធម៌នឹងព្រះអង្គ ។

**ខ្លឹមសារ** ការឆ្លើយតបបញ្ហាធម៌ ១៤ មុខ ។

២២- **មហាសតិប្បដ្ឋានសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **កម្មាសទម្មនិគម** ក្នុងដែនកុរុ ។ ព្រះអង្គទ្រង់ប្រារព្ធភិក្ខុទាំងឡាយ ត្រាស់សម្ដែងសតិប្បដ្ឋានសូត្រ ។

**ខ្លឹមសារ** មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។

សិក្សាខ្លឹមសារជាចំណុចៗ មានដូចតទៅ :

១- គ្រប់បព្វៈ គ្រប់ធម៌ទាំងអស់ ក្នុងមហាសតិប្បដ្ឋានសូត្រ គឺជាទីតាំងនៃសតិរលឹកសិក្សា ឬថាជាអារម្មណ៍របស់សតិ ។

២- មិនមែននៅក្នុងគំនិតមានខ្លួនយើង រៀបចំបព្វៈនេះ ឬកន្លែងនេះ ពេលនេះ ដើម្បីចម្រើនសតិប្បដ្ឋាននោះទេ គឺគ្រប់ព្រះអង្គ គ្រប់គ្នា គ្រប់កន្លែង គ្រប់ពេលវេលា សុទ្ធតែមានធម៌ជាទីតាំងនៃសតិរលឹកបានទាំងអស់ ធម៌ជាប្រក្រតី មិនមែនជាអត្តាតួខ្លួនយើងហើយស្រេច ។ កាលណា បើធម៌ជាប្រក្រតីប្រាកដ

លក្ខណៈមិនមែនជាអត្តាតួខ្លួនយើងហើយ ពុទ្ធបរិស័ទនឹងបាន ចេះដឹងច្បាស់ក្នុងចំណុចទី ២ នេះ បានដឹងការមានសតិថ្នាក់សតិប្បដ្ឋាន ខុសអំពីការដែលអត់មានសតិថ្នាក់សតិប្បដ្ឋាននោះឯង និងបានយល់ច្បាស់ថាអ្វីដែលជាទីតាំងនៃសតិរលឹកសិក្សា ព្រមទាំងបានយល់អំពីវិបស្សនា ដែលជាតួដឹងច្បាស់ចំពោះអ្វីៗនោះ ។

៣- សតិថ្នាក់សតិប្បដ្ឋាន មានបច្ច័យទើបកើតឡើងបាន សតិនេះឯងជាសង្ខារក្ខន្ធ សត្វបុគ្គលតួខ្លួនអ្នកឱ្យសតិកើតអត់មានទេ ប៉ុន្តែអាស្រ័យការបានស្តាប់យល់តួធម៌ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងប្រាប់ ក៏ជាបច្ច័យឱ្យមានការសិក្សាសង្កេតពិនិត្យរឿយៗ នូវតួធម៌នោះ រហូតដល់ឱ្យសតិថ្នាក់សតិប្បដ្ឋាននេះកើតឡើង សូម្បីអារម្មណ៍របស់សតិ ក៏ជាអារម្មណប្បច្ច័យនៃសតិផងដែរ ។

៤- ពាក្យថាបុគ្គលអ្នកព្យាយាមចម្រើនសតិប្បដ្ឋាន ជាវោហារដោយសម្មតិកថា តែបើដោយបរមត្ថកថា គឺវីរិយចេតសិក ប្រព្រឹត្តទៅជាមួយនឹងសតិប្បដ្ឋានហ្នឹងឯង ។

៥- ស្តាប់ធម៌ គឺស្តាប់ឱ្យយល់ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងប្រាប់ អ្វីជាធម៌ ។ ធម៌ជាកុសល ធម៌ជាអកុសល

ធម៌ជាអព្យាក្រឹត ។ បើស្តាប់អំពីអកុសលធម៌ មានលោភៈ ទោសៈ មោហៈ ឬកាមច្ឆន្ទៈជាដើម ហើយក្នុងគំនិតប្រកាន់ថា ជាកិលេសរបស់ខ្លួន ដូច្នេះ សតិប្បដ្ឋាន (សតិ ) រមែងមិនមានឡើយ សូម្បីមានគំនិតគិតថា ត្រូវចម្រើនសតិប្បដ្ឋានដើម្បីលះកិលេសនោះៗ ក៏ដោយ មានតែចិត្តចង្អៀតចង្អល់ ទាស់នឹងកិលេស ខ្វល់នឹងឱ្យខ្លួនឯងអស់កិលេស គិតចង់បដិបត្តិធម៌ តើត្រូវបដិបត្តិយ៉ាងដូចម្តេចជាដើម ប៉ុន្តែ បើស្តាប់យល់អំពីអកុសលធម៌ កិលេសមានលោភៈជាដើម ជាប្រក្រតីក្នុងជីវិត ជាធម៌មានពិត កុសលក៏ជាតួធម៌ពិត រូបពិត វិបាកពិត ដូច្នេះ សតិប្បដ្ឋានរមែងមាន ដោយអត់ខ្វល់នឹងឱ្យខ្លួនឯងចម្រើនសតិប្បដ្ឋាន ដើម្បីនឹងបានលះបង់នូវកិលេសនោះៗឡើយ ហើយក៏អត់មានអ្នកដទៃណា មកបង្គាប់ឱ្យចម្រើនសតិប្បដ្ឋានដែរ ។

៦- កិលេសទាំងអស់ ជាធម៌ដែលត្រូវលះបង់ ប៉ុន្តែត្រូវលះបង់ដោយអរិយមគ្គ មានសតិប្បដ្ឋានជាបុព្វភាគ មិនមែននៅក្នុងគំនិតប្រកាន់កិលេសរបស់យើង ហើយទោមនស្ស ប្រទូស្តទាស់ចំពោះកិលេសនោះៗទេ ។

៧- សេចក្តីស្ងប់ក្នុងចិត្ត មិនមែននៅត្រង់ចង់បានសេចក្តីស្ងប់ទេ តែនៅត្រង់រលឹកដឹងចិត្ត ដែលកំពុងមាន កំពុងប្រាកដ ។

កាលដែលមិនប្រកាន់ចិត្តជាបច្ចុប្បន្ន ឃើញចិត្តបច្ចុប្បន្នជាធម៌ត្រូវលះបង់ទៅហើយ ដូច្នេះ មានត្រូវការប្រាថ្នាចង់បានចិត្តស្ងប់យកមកឱ្យអ្នកណា នេះឯងជាសេចក្ដីស្ងប់ពិត ស្ងប់ក្នុងវិបស្សនា ។

៨- បើពុទ្ធបរិស័ទប្រាថ្នាតាមព្រះពុទ្ធអង្គ ក្នុងដំណើរចេញពីលោកនេះ ទៅព្រះនិព្វាន គឺមានតែផ្លូវសតិប្បដ្ឋាននេះឯង ។ កំណត់នាមរូបជាប្រក្រតី មិនមែនជាយើង ទុកដាក់នាមរូបជាធម៌ក្នុងលោក ដូច្នេះពុទ្ធបរិស័ទពិតជាមិននៅក្នុងលោកនេះឡើយ ឈ្មោះថា បានដង្ហែព្រះពុទ្ធអង្គទៅកាន់ព្រះនិព្វាន ។

៩- សតិប្បដ្ឋាន មិនប្រព្រឹត្តទៅដើម្បីបានអ្វីពីក្នុងលោកនេះឡើយ ហើយក៏អត់ទោមនស្សជាមួយនឹងអ្វីៗដែរ ប៉ុន្តែលះបង់ការមិនដឹងនូវសភាវធម៌តាមសេចក្ដីពិត ។

១០- ពុទ្ធបរិស័ទ ច្រើនតែចង់ឱ្យខ្លួនឯងអស់កិលេស ឃើញទោសនៃការខឹងក្រោធ ឃើញទោសនៃការប្រកាន់តួខ្លួនជាដើម ប៉ុន្តែមិនឃើញទោសនៃអវិជ្ជាគឺការមិនដឹងធម៌ទាំងពួងតាមសេចក្ដីពិត ។ សតិប្បដ្ឋានបដិបក្ខដោយត្រង់ចំពោះអវិជ្ជានេះឯង ។

១១- សតិប្បដ្ឋានរលឹកដឹងធម៌តាមសេចក្ដីពិត រមែងប្រព្រឹត្តទៅជាផ្លូវកណ្ដាលអភិជ្ឈានិងទោមនស្ស ហើយក៏ជាការលះបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកហ្នឹងឯង ។

២៣- **បាយាសិរាជញ្ញសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់ដោះប្រស្នា ១៥ ចំណុច ក្នុងវម្មិកសូត្រ ញាំងព្រះកុមារកស្សបៈឱ្យបានសម្រេចព្រះអរហត្ត និងបានស្ថាបនាតែងតាំងឱ្យលោកជាកំពូលលើភិក្ខុទាំងឡាយ ផ្នែកខាងសម្តែងធម៌ដ៏វិចិត្រ ព្រោះប្រារព្ធហេតុកើតឡើង គឺព្រះកុមារកស្សបៈ បានសម្តែងធម៌ឆ្លើយបញ្ហាក្នុងបាយាសិរាជញ្ញសូត្រនេះឯង ។

**ខ្លឹមសារ** ដោះស្រាយបញ្ហាមិច្ឆាទិដ្ឋិ ដែលព្រះបាទបាយា-សិរាជញ្ញៈ យល់ថា សត្វស្លាប់ទៅសូន្យ មិនកើតទៀត ផលបុណ្យផលបាបមិនមាន ។

២៤- **បាដិកសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **អនុប្បិយនិគម** ក្នុងមល្លជនបទ ។ ព្រះអង្គទ្រង់ប្រារព្ធ ភគ្គវ-គោត្របរិព្វាជក ឆ្លើយបញ្ហាដែល ភគ្គវគោត្រ ទូលសួរអំពីសុនក្ខត្តលិច្ឆវិបុត្រ ។

**ខ្លឹមសារ** ឧបនិស្ស័យរបស់សុនក្ខត្តលិច្ឆវិបុត្រ ជ្រះថ្លានឹងពួកអចេលកៈ ទាំងដែលខ្លួនលោកកំពុងឋិតនៅក្នុងភាវៈជាភិក្ខុ លោកថែមទាំងមើលងាយព្រះពុទ្ធដីកា ហើយគាំទ្រយ៉ាងខ្លាំងចំពោះអចេលកៈ ឈ្មោះបាដិកបុត្រទៀតផង ។

២៥- **ឧទុម្ពរិកសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើ **ភ្នំគិជ្ឈកូដ** ជិតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ប្រារព្ធនិគ្រោធ-បរិព្វាជកដែលតិះដៀលថា ព្រះសមណគោតម ជាបុគ្គលមិនហ៊ាន ចុះកាន់បរិស័ទ មិនអាចធ្វើការចរចានឹងអ្នកដទៃបាន ប្រាជ្ញារបស់ព្រះអង្គ វិនាសបាត់ក្នុងផ្ទះស្ងាត់អស់ទៅហើយ ដូច្នេះជាដើម ទាំងបានប្រៀបព្រះអង្គទៅនឹងមេគោខ្វាក់ភ្នែកម្ខាងទៀតផង ។ ព្រះដ៏មានព្រះភាគ ទ្រង់យាងចុះពីភ្នំមកកាន់ឧទុម្ពរិការាម ជាអារាមដែលនិគ្រោធបរិព្វាជកនៅជាមួយនឹងបរិស័ទ ៣០០០ នាក់ ព្រះអង្គទ្រង់សន្ទនាជាមួយនឹងនិគ្រោធបរិព្វាជក អំពីតបៈខ្ពើមបាប រហូតដល់និគ្រោធបរិព្វាជកសូមខមាទោសចំពោះព្រះអង្គ ។

**ខ្លឹមសារ** មគ្គព្រហ្មចរិយធម៌ ជាកំពូលនៃតបៈទាំងពួង ឧត្តមជាង វិសេសជាង ។

២៦- **ចក្កវត្តិសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាដងព្រៃ ជិត **មាតុលានគរ** ក្នុងដែនមគធៈ ។ ព្រះអង្គទ្រង់ប្រារព្ធឧបនិស្ស័យព្រះអរហត្តនៃព្រះភិក្ខុសង្ឃ ២ ម៉ឺនអង្គ និងឧបនិស្ស័យមគ្គផលរបស់អ្នកស្រុកក្នុងមាតុលានគរ ព្រះអង្គទ្រង់ត្រាស់សម្តែងឱ្យមានសតិប្បដ្ឋាន ៤ ជាទីពឹង ។

**ខ្លឹមសារ** បុណ្យនេះ រមែងចម្រើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ យ៉ាងនេះឯង គឺសិរីសម្បត្តិរបស់ស្តេចចក្រ ជាផលលោកិយក្នុងមនុស្សលោក និងព្រះអរហត្តកម្ចាត់អស់កិលេស ជាផលលោកុត្តរ ។ បុគ្គលជាឧទាហរណ៍ គឺព្រះបាទសង្ខៈ ជាស្តេចចក្រ ជាធម្មិកោ ធម្មរាជា ព្រះអង្គបានលះបង់សម្បត្តិស្តេចចក្រ រតនៈ ៧ ប្រការជាដើម ចូលកាន់ផ្នួសក្នុងព្រះពុទ្ធសាសនានៃព្រះមេត្តេយ្យៈ សម័យកាលមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ហើយសម្រេចព្រះអរហត្ត ជាព្រះអរហន្តមួយព្រះអង្គ ។

២៧- **អគ្គញ្ញសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ**បុព្វារាម** ជិតក្រុងសាវត្ថី ។ ព្រះអង្គទ្រង់ប្រារព្ធសាមណេរពីរអង្គ គឺវាសេដ្ឋសាមណេរ និងភារទ្វាជសាមណេរ សម្តែងអំពីវណ្ណៈទាំង ៤ ដែលមានប្រវត្តិតាំងពីបឋមកប្ប មានការសន្មតពីមនុស្សទាំងឡាយក្នុងកាលនោះ ។

**ខ្លឹមសារ** ខត្តិយៈជាជាតិប្រសើរបំផុត ក្នុងប្រជុំជន ដែលជាអ្នករលឹកដល់គោត្រ ចំណែកបុគ្គលដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺប្រសើរបំផុតក្នុងពួកមនុស្សនិងទេវតាទាំងឡាយ ។

២៨- **សម្បសាទនីយសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **នាឡន្ទាវិហារ** ក្នុងស្រុកនាឡន្ទា (បច្ចុប្បន្នគឺមហាវិទ្យាល័យនាឡន្ទា ដែលមានស្តូបព្រះសារីបុត្ត ) ។ ព្រះអង្គទ្រង់ប្រារព្ធព្រះសារីបុត្ត ដែលបន្លឺអាសភិវាចា គឺវាចាដ៏អង់អាច ពោលគឺព្រះសារីបុត្ត បានបន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ យ៉ាងនេះថា សមណៈឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលប់ ជាងព្រះដ៏មាន-ព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខក៏មិនមាន ទាំងក្នុងកាលឥឡូវនេះ ក៏មិនមាន ។ កាលដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សួរហើយ ព្រះសារីបុត្តបានក្រាបទូលព្រះអង្គអំពីអនុមានញ្ញាណ តាមកម្លាំងនៃសាវកបារមី-ញាណរបស់លោក ។

**ខ្លឹមសារ** ធម្មទេសនាដ៏ប្រសើរខ្ពង់ខ្ពស់របស់ព្រះដ៏មាន-ព្រះភាគ ដែលព្រះសារីបុត្តបានលើកយកមកប្រកាសសម្តែងដោយប្រការផ្សេងៗ គួរជាទីជ្រះថ្លាណាស់ ។

២៩- **បាសាទិកសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **វេធញ្ញប្រាសាទ** ក្នុងអម្ពវ័នរបស់ពួកសក្យៈ នាសក្កជនបទ ។

ព្រះអង្គទ្រង់ប្រារព្ធរឿងរ៉ាវដែលពួកនិគ្រន្ថបែកបាក់គ្នា តាមដែលព្រះចុន្ទៈ និងព្រះអានន្ទ បានក្រាបទូលព្រះអង្គ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងធម៌គួរជាទីជ្រះថ្លា គឺធម្មវិន័យដែលព្រះអង្គបានប្រកាសល្អហើយ ។

**ខ្លឹមសារ** ការព្រមព្រៀងគ្នានៃពុទ្ធបរិស័ទរួបរួមធម៌វិន័យផ្ទៀងផ្ទាត់អត្ថនិងព្យញ្ជនៈ ព្រមទាំងចម្រើនសតិប្បដ្ឋាន ៤ លះបង់នូវពួកទិដ្ឋិនិស្ស័យ ជាដើម ។

៣០- **លក្ខណសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាមហាវិហារព្រះជេតពន ជិតក្រុងសាវត្ថី ។ ព្រះអង្គទ្រង់ប្រារព្ធភិក្ខុទាំងឡាយ ត្រាស់សម្តែងនូវមហាបុរិសលក្ខណៈ ៣២ ប្រការព្រមទាំងបុញ្ញកម្មដែលជាបច្ច័យនៃរូបលក្ខណៈដ៏វិសេសៗទាំង ៣២ ប្រការនេះ ។ ពួកឥសីជាខាងក្រៅ តែងចេះចាំនូវមហាបុរិស-លក្ខណៈរបស់មហាបុរសទាំង ៣២ នេះឯង ប៉ុន្តែឥសីទាំងនោះឥតដឹងសោះថា ព្រោះមហាបុរសបានធ្វើនូវកម្មអ្វី ទើបបាននូវលក្ខណៈនេះ ។

**ខ្លឹមសារ** មិនមានផលសម្រេចណា ដែលកើតឡើងឯងៗនោះទេ គឺត្រូវតែអាស្រ័យហេតុសម្បទា ។

៣១- **សិង្គាលកសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនា **មហាវិហារព្រះវេឡុវ័ន** ជិតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ប្រារព្ធសិង្គាលកមាណព ដែលគោរពថ្វាយបង្គំទិសទាំង ៦ ត្រាស់សម្តែងអំពីបាបធម៌ ១៤ យ៉ាងដែលព្រះអរិយសាវក័បានលះបង់ហើយ គឺកម្មក្កិលេស ៤ បាបកម្មព្រោះអគតិ ៤ និងអបាយមុខ ៦ ព្រមទាំងព្រះអង្គទ្រង់ត្រាស់សម្តែង អំពីធម៌សង្គ្រោះគ្នាទៅវិញទៅមកដែលជាទិសនៃសេចក្តីគោរពទាំង ៦ ។

**ខ្លឹមសារ** ធម៌សម្រាប់អ្នកគ្រប់គ្រងផ្ទះ មានជ័យជម្នះទាំងក្នុងលោកនេះ ទាំងក្នុងបរលោក ។

៣២- **អាដានាដិយសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើ **ភ្នំគិជ្ឈកូដ** ជិតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ប្រារព្ធអាដានាដិយបរិត្ត ដែលស្តេចវេស្សវណ៍ទូលថ្វាយ ត្រាស់សម្តែងឱ្យភិក្ខុទាំងឡាយចងចាំទុក ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។

**ខ្លឹមសារ** អាដានាដិយបរិត្ត មានអានុភាពពិត ឋិតនៅត្រង់នមស្ការព្រះជិនស្រី ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ។

៣៣- **សង្គីតិសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ **អម្ពវ័ន**របស់នាយចុន្ទកម្មារបុត្រ ជិតក្រុងបាវា ព្រមដោយភិក្ខុ ៥០០ អង្គ ។ ព្រះអង្គទ្រង់ប្រារព្ធភិក្ខុទាំង ៥០០ អង្គនោះ ដែលមានឧបនិស្ស័យព្រះអរហត្ត ព្រះអង្គបានត្រាស់ចាត់ឱ្យព្រះសារីបុត្តសម្ដែងព្រះធម៌ ។

**ខ្លឹមសារ** សង្គាយនានូវធម៌ដែលព្រះដ៏មានព្រះភាគ បានប្រកាសសម្ដែងទុកល្អហើយ ជានិយ្យានិកធម៌ ប្រព្រឹត្តទៅដើម្បីស្ងប់រំងាប់ និងដើម្បីការតាំងនៅអស់កាលជាយូរអង្វែងនៃព្រហ្មចរិយធម៌ ។

៣៤- **ទសុត្តរសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរស្រះ **បោក្ខរណី** ឈ្មោះ **គគ្គរា** ជិតក្រុងចម្ប៉ា ដែនអង្គៈ ព្រមដោយភិក្ខុ ៥០០ អង្គ ។ ព្រះអង្គទ្រង់បានបញ្ជូនភិក្ខុទាំងនោះមកកាន់សម្នាក់ព្រះសារីបុត្ត ទៅតាមឧបនិស្ស័យដែលព្រះអង្គទ្រង់ជ្រាប ។ ព្រះសារីបុត្ត បានពិចារណាឃើញធម៌ជាទីសប្បាយនៃភិក្ខុសង្ឃដែលព្រមព្រៀងគ្នា បានប្រកាសសម្ដែងធម៌ជាពួកៗ ចាប់ពីធម៌មួយ ១០ ដង ឡើងទៅដល់ធម៌ដប់ ១០ ដង ។

**ខ្លឹមសារ** ពួកធម៌សម្រាប់សិក្សាស្រាយនូវចំណងគឺកិលេសជាគ្រឿងចាក់ស្រែះ មានចំនួនធម៌ ៥៥០ គឺពួកដប់មាន ១០០ ធម៌ ពួកមួយនិងពួកប្រាំបួនមាន ១០០ ធម៌ ពួកពីរនិងពួកប្រាំបីមាន ១០០ ធម៌ ពួកបីនិងពួកប្រាំពីរមាន ១០០ ធម៌ ពួកបួននិងពួកប្រាំមួយមាន ១០០ ធម៌ និងពួកប្រាំមាន ៥០ ធម៌ ។



## ១. គគីរធន់ទឹក ធ្នឹកធន់ដី

រុក្ខជាតិក្នុងព្រៃតម្លៃខ្ពស់ នៅសល់តែឈ្មោះចារចងចាំ
ខំប្រឹងលួតលាស់អស់រយឆ្នាំ ត្រូវកាប់ចិញ្ច្រាំឥតគិតក្រែង ។
គ្រញូងបេងក្លាយជានាងពួន កកោះនាងនួនពួនតុបតែង
ផ្ចង់ត្រាចឈើទាលវាលបែកផ្សេង ដុតទាំងខ្លុងត្បែងគ្មានសល់អ្វី ។
បំណាច់ប្រើឈើមើលឱ្យច្បាស់ ដ្បិតមានឈើខ្លះចាញ់ឫស្សី
គគីរធន់ទឹក ធ្នឹកធន់ដី លែលកធ្វើអ្វីតាមសាច់ឈើ ។
ក្រុមអ្នកធឹកស៊ីឱ្យលីសែង អ្នកចេះចាត់ចែងឱ្យការធ្វើ
ចេះពិតឥតឆ្មើងឱ្យឡើងលើ ចេះចាក់រុករើចាប់ចេញចុះ ។
កិច្ចការគរគោកលោកខន្ធប្រាំ ទីចាត់ការកម្មរៀបឥតខុស
មានបុណ្យឱ្យឡើងបាបឱ្យចុះ គ្រប់រូបស្រីប្រុសកម្មចាត់ចែង ។

ដោយឧបាសក **គុយ សុធន**

## ២. ចេះតិចប្រើកាយជឿវាយគិតខ្លី

សុរិយារះរេទេរទន់ទាបទៅ បាំងនឹងព្រៃជ្រៅផ្លូវនៅឃើញច្បាស់
រួតដំណើរទៅទាន់នៅភ្លឺខ្លះ ទុក្ខទោសច្រើនណាស់ព្រៃក្រាស់ងងឹត ។
ជីវិតនេះណាជាការតស៊ូ ឧបសគ្គជាគ្រូជួរចត់មែនពិត
លំបាកម្តេចក្តីគប្បីរិះគិត បើដឹងការពិតជីវិតស្ងប់ស្ងាត់ ។

ចេះតិចរមែងតែងតែស្តាយក្រោយ ប្រើកាយក៏ដោយត្រូវឱ្យប្រយ័ត្ន
ជឿងាយទាយផ្សំនាំមានវិបត្តិ មរណាមកកាត់ជ្បិតតែគិតខ្លី ។
បើចង់គិតអ្វីគិតលៃឱ្យវែង កុំធ្វើដូចក្មេងដែលនៅលេងដី
សូម្បីតែក្មេងលេងឥតគិតខ្លី ឥតគិតប្រល័យជីវិតខ្លួនឡើយ ។

ដោយឧបាសក **គុយ សុធន**

## ៣. ប្រឡងចប់ចូលធ្វើការ

ស្រេកឃ្លានមានទុក្ខមុខគួរអាណិត នឹកស្ទើរខ្លោចចិត្តជ្បិតតែរូបកូន
បណ្តាំពុកម៉ែឱ្យថែបងប្អូន ផលមិនសាបសូន្យកូនត្រូវចាំថា ។
កិច្ចការសមគួរតាមតួនាទី កូនកុំរក់រីស្រីញីល្បែងស្រា
ចង់ដើរត្រង់ផ្លូវត្រូវខំសិក្សា រៀនចប់កាលណារក្សាគុណធម៌ ។
ត្រូវប្រឡងចេញពីទីអុងអាត់ យកសញ្ញាបត្រជាមនុស្សបវរ
កូនកុំចេញពីថ្នាក់អប់រំល្អ ចាប់យករបរ តពីចោរអី ។

ដោយឧបាសក **គុយ សុធន**

## ៤. ឱកូនអើយ

ជំនន់ឡើងជោរជំនោរត្រជាក់ ចិត្តជាប់ជំពាក់អ្នកនៅទីណា
ម៉ែឪនឹកកូនស្ទើរសូន្យសង្ខារ សងសឹកសង្សារថាលែងរស់នៅ ។

ដោយឧបាសក **គុយ សុធន**

## ៥. អារាធនាព្រះធម៌ទេសនា

សូមក្រាបថ្វាយបង្គំ ឆ្ពោះព្រះបរមសាស្តា
ជាគ្រូមនុស្សទេវ្តា និងព្រហ្មលោកទាំងបី ។
និងក្រាបថ្វាយបង្គំ ឆ្ពោះឧត្តមព្រះធម៌ថ្លៃ
ព្រះសង្ឃសាវក័នៃ អង្គជិនស្រីព្រះទ្រង់ញាណ ។
សូមថ្វាយបង្គំផ្ចង់ ឆ្ពោះតម្រង់អង្គទូន្មាន
ដឹកនាំដាក់ធម្មយាន សូមប្រទានធម៌ឧត្តម ។
លោកនៃការរស់នៅ ក្នុងជម្រៅទុក្ខជោកជាំ
ក្នុងព្រះអភិធម្ម គឺអារម្មណ៍របស់ចិត្ត ។
តែយើងខ្ញុំទាំងឡាយ សែនខ្វល់ខ្វាយវិលគំនិត
ចំណង់ខុសការពិត នាំឱ្យចិត្តរឹតខ្លោចផ្សា ។
ជំនន់នៃកិលេស ឡើងពុំចេះស្រកពេលណា
សត្វលង់ក្នុងជលសា ឃើញភេត្រាថាពុំត្រូវ ។
ហេតុនេះសូមព្រះអង្គ ជួយស្រោចស្រង់តម្រង់ផ្លូវ
ទូន្មានប្រៀនប្រដៅ គ្រាឥឡូវនៅទីនេះ ។

**សូមអនុមោទនា !**

ដោយឧបាសក **គុយ សុធន**

# ៦. ជួបធម្មមិត្តពិតជាល្អ

(ពាក្យប្រាំបី)

ជីវិតមនុស្សសត្វវិបត្តិតែងមាន　រងទុក្ខស្រេកឃ្លានមានភយន្តរាយ
ក្នុងវដ្តសង្សារដ៏មហាវែងឆ្ងាយ　ធ្លាប់ធ្លាក់អបាយស្តាយអ្វីម្ល៉េះទេ ។
រស់នៅទីក្រុងក្នុងភាពអ៊ូអែ　រស់នៅស្រុកស្រែមិនដែលទំនេរ
នៅក្នុងព្រៃស្ងាត់មានសត្វបំពេ　នៅស្រុកទន្លេផ្ទះផែលើទឹក ។
រស់នៅថ្ងៃយប់គ្រប់ទីកន្លែង　សុទ្ធតែប្រឹងប្រែងចំបែងតែងនឹក
ក្នុងការរួមរស់ទោះគោកឬទឹក　មានអ្នករំលឹកប្ញកពិតល្អជា ។
ជួបនឹងធម្មមិត្តពិតជាបវរ　នាំបានស្តាប់ធម៌ល្អ ឥត្ថា
បានស្តាប់ព្រះធម៌ល្អគ្រប់វេលា　នាំឱ្យសទ្ធាកើតជាប្រចក្ស ។
សទ្ធាចូលដល់តម្កល់ចិត្តល្អ　នាំកុសលធម៌កើត ត ឥតអាក់
មានយោនិសោមនសិការៈ　កុសលច្រើនថ្នាក់បណ្តាក់គ្នាកើត ។
សទ្ធារឹងមាំដឹកនាំគំនិត　រួមផ្សំធម្មមិត្តបានគិតបង្កើត
ធ្វើបុណ្យទានមានទាំងខួបកំណើត　រនោចឬខ្មែតបង្កើតថ្ងៃល្អ ។
ចង្ហាន់ផ្ចិតផ្ចង់ធ្វើសង្ឃទាន　ចំណាយធនធានទោះមានឬក្រ
និមន្តលោកតាទេសនាព្រះធម៌　សន្សំសាងល្អបន្តអប់រំ ។
វត្តមានធម្មមិត្តជាកិត្តិយស　ឧត្តមខ្ពង់ខ្ពស់របស់យើងខ្ញុំ
បើការទទួលមិនបានសមរម្យ　អត់ទោសឱ្យខ្ញុំទាំងអស់គ្នាផង ។

សូមឧទ្ទិសផលដល់ធម្មញាតិមិត្ត សូមជួបធមិពិតដូចចិត្តបំណង
បានសុខចម្រើនកុំបីសៅហ្មង សូមឱ្យបានឆ្លងផុតពីទុក្ខភ័យ ។

ដោយឧបាសក **គុយ សុធន**

## ៧- ជួបធម្មមិត្តពិតជាល្អ

(ពាក្យប្រាំពីរ)

ជីវិតមនុស្សសត្វក្នុងលោកា រងទុក្ខខ្លោចផ្សាភយន្តរាយ
ក្នុងវដ្តសង្សារមហាវែងឆ្ងាយ ធ្លាប់ធ្លាក់អបាយមានចាំទេ ។
រស់នៅទីក្រុងជុំអ៊ូអែ រស់នៅស្រុកស្រែឥតទំនេរ
នៅក្នុងព្រៃស្ងាត់សត្វបំពេ នៅស្រុកទន្លេផែលើទឹក ។
រស់នៅថ្ងៃយប់គ្រប់កន្លែង សុទ្ធតែប្រឹងប្រែងចំបែងនឹក
ក្នុងការរួមរស់ទោះគោកទឹក មានអ្នករំលឹកពិតល្អជា ។
ជួបនឹងធម្មមិត្តពិតបវរ នាំបានស្តាប់ធមិលម្អគ្នា
បានស្តាប់ព្រះធមិល្អគ្រប់គ្រា នាំឱ្យសទ្ធាកើតប្រចក្ស ។
សទ្ធាចូលដល់តម្កល់ល្អ កើតកុសលធមិ ត ឥតអាក់
មានយោនិសោមនសិការៈ កុសលច្រើនថ្នាក់ក៏ចាប់កើត ។
សទ្ធារឹងមាំដឹកនាំចិត្ត រួមផ្សំធម្មមិត្តគិតបង្កើត
ធ្វើបុណ្យឱ្យទានខួបកំណើត រនោចឬខ្មើតសុទ្ធតែល្អ ។
ចង្ហាន់ផ្ចិតផ្ចង់ធ្វើសង្ឃទាន ចំណាយធនធានទោះមានក្រ
មន្តលោកទេសនាស្តាប់ព្រះធមិ សន្សំសាងល្អខំអប់រំ ។

វត្តមានធម្មមិត្តជាកិត្តិយស ឧត្តមខ្ពង់ខ្ពស់នៃយើងខ្ញុំ
បើការទទួលមិនសមរម្យ មេត្តាឱ្យខ្ញុំសុំទោសផង ។
សូមឧទ្ទិសផលដល់ញាតិមិត្ត សូមជួបធម៌ពិតដូចបំណង
បានសុខចម្រើនឥតសៅហ្មង សូមឱ្យបានឆ្លងផុតទុក្ខភ័យ ។

ដោយឧបាសក **គុយ សុធន**

# ៨. សន្ធារីខមាំព្រោះធម្មទាន

ជីវិតសព្វសត្វ តែងមានវិបត្តិ កម្មកាត់ទោសឱ្យ
ឃើញតែសុខតិច ភ្លេចទុក្ខតាមក្រោយ ផលបុណ្យខ្សត់ខ្សោយ
ឱ្យបាបតាមទារ ។

ជួបភយន្តរាយ ទុក្ខទោសវែងឆ្ងាយ កាយចិត្តគ្រាំគ្រា
ព្រោះតែធ្លាប់ធ្វើ អំពើពាលា រងទុក្ខវេទនា
ទល់គ្រាអស់កម្ម ។

រស់នៅឆ្ងាយជិត បានជួបធម្មមិត្ត ចិត្តគិតចំណាំ
ដូចសប្បុរស ជួយរំដោះកម្ម នាំកាន់សីលប្រាំ
ចាំជួយផ្សែផ្សំ ។

ជួយប្រាប់ជួយថា នាំស្តាប់ទេសនា ចិន្តាស្អាតស្អំ
ស្រាកទុក្ខគ្រាំគ្រា សទ្ធារួមផ្សំ រួមគ្នារៀបចំ
ធ្វើបុណ្យឱ្យទាន ។

ចង្ហាន់ផ្ចិតផ្ចង់ រាប់បាត្រថ្វាយសង្ឃ ចាយទ្រព្យធនធាន
សទ្ធារឹងមាំ ក៏ព្រោះធម្មទាន រៀបចំឱ្យមាន
ព្រះធម៌ទេសនា ។
ស្ដាប់ធម៌ពីរោះ កុសលឡើងខ្ពស់ រស់មានខ្លឹមសារ
អញ្ជើញញាតិមិត្ត ពិសាអាហារ ក្នុងថ្ងៃនេះណា
ដោយក្ដីស្ម័គ្រស្មោះ ។
វត្តមានធម្មមិត្ត និងញាតិឆ្ងាយជិត ជាកិត្តិយស
ឱ្យគ្រួសារខ្ញុំ ឧត្ដមខ្ពង់ខ្ពស់ ជាសាក្សីរស់
ព្រោះបានធ្វើបុណ្យ ។
សូមឧទ្ទិសផល គោរពជូនដល់ លោកអ្នកមានគុណ
ជូនដល់ញាតិមិត្ត នេះពិតជាបុណ្យ ទុកជាដើមទុន
ទៅព្រះនិព្វាន ។

ដោយឧបាសក **គុយ សុធន**

## ៩_ សង្គ្រាម

សំឡេងគគ្រឹមគ្រហឹមតជាប់ ស្នូរបាញ់សន្ធាប់ញាប់ញ័រសព្វកាយ
ច្បាំងស្លាប់របួសរងគ្រោះអត់បាយ ព្រាត់ប្រាសអន្តរាយសោកស្ដាយក្រៃលែង ។

ដោយឧបាសក **គុយ សុធន**

# ១០~ បុណ្យផ្កាសាមគ្គី

រូបតាំងនៅបានអាស្រ័យអាហារ ជីវិតមច្ឆាអាស្រ័យគង្គា
ឆ្លងសមុទ្រប្រែអាស្រ័យនាវា រាស្ត្ររស់សុខជាអាស្រ័យមហាក្សត្រ ។
កូនរស់អាស្រ័យមាតាបិតា វិន័យសិក្ខាអាស្រ័យបដិបត្តិ
សង្ឃគង់នៅបានអាស្រ័យបរិស័ទ ស្រុកមានវិបត្តិព្រោះបែកបាក់គ្នា ។
ឥឡូវបរិស័ទស្អាត់មកជួបជុំ រៀបចំសមរម្យជុំដោយសទ្ធា
ធ្វើផ្កាសាមគ្គីយកប្រាក់បូជា កសាងខ្លោងទ្វារវិហារសាលា ។
រៀបចំចាត់ចែងបែងចែកការងារ បង្កើតបានជាគណៈកម្មការ
មានចិត្តស្ម័គ្រស្មោះចំពោះសាសនា ធ្វើជាបុណ្យផ្កាសាមគ្គីកសាង ។
ថ្ងៃនេះថ្ងៃបុណ្យដូចបានប្រចក្ស មានដើមផ្កាប្រាក់ដាក់ជាភ័ស្តុតាង
សូត្រធម៌ទេសនាអាចារ្យស្មូតខាង តំណាងព្រហ្មាអារាធនាព្រះ ។
សូមបុណ្យដែលយើងបានរួបរួមគ្នា តាមវត្តនានាឬរោងមុខផ្ទះ
ប្រមូលបច្ច័យដែលរៃអង្គាស បូជាសំពះរូតរះសាងសង់ ។
សូមឱ្យគ្រប់ជាតិរហូតតទៅ ឥតខ្វះលំនៅសម្បត្តិផ្លូវផង់
បានជួបព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ទ្រង់ជួយតម្រង់ត្រង់ព្រះនិព្វាន ។

ដោយឧបាសក **គុយ សុធន**

## ១១. ឃ្មុំក្រេបផ្កា

សង្ឃមានកិច្ចវត្តអត់ប្រមាទ និមន្តបិណ្ឌបាតតាមវេលា
មិនឱ្យបរិស័ទខូចសទ្ធា គោរពបូជាដោយជ្រះថ្លា ។
ប្រៀបដូចសត្វឃ្មុំហើរលីលា ស្រង់តាមគន្ធារកបុប្ផ
បានជួបហើយក្រេបលម្អងផ្កា មិនឱ្យបុប្ផខូចសម្រស់ ។

ដោយឧបាសក **គុយ សុធន**

## ១២. អ្នកមានចំណេះ

សិក្សាមានគ្រូយូរឆាប់គង់ចេះ អ្នកមានចំណេះគង់ចេះស្ដីថា
បើធ្វើការងារដូចជាវាចា នោះជាតិសាសនាមហាចម្រើន ។

## ១៣. ហេតុពិត

អ្នកអត់ជំងឺសាច់ភ្លឺរលោង អ្នកខ្សោយបេះដូងក្នុងទ្រូងញាប់ញ័រ
ស្ដេចមានវិបត្តិស្វាត់ព្រះនគរ រាស្ត្រអត់គុណធម៌រីកវរសង្គម ។

## ១៤. ខ្ញុំចិត្តអញអើយ

ហួបចុករាល់ថ្ងៃអាស្រ័យនៅរស់ កើតជាជម្លោះព្រោះតែទាស់ចិត្ត
បំពង់កស្ទះក្រពះក្រៀមស្ងិត រូបកាយស្គមពិតចិត្តខ្លាំងលើសដើម ។

ដោយឧបាសក **គុយ សុធន**

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការងារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វេងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក ទូច គីមស្រ៊ាង |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូដា | ២០. ឧបាសិកា ហាយច័ន្ទធរី |
| ២១. ឧបាសក អ៊ឹម វ៉ៃយ៉ា | ២២. ឧបាសក ហង់ វណ្ណៈ |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

| | | |
|---|---|---|
| ១- | លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា +បុត្រ ..... | ស.រ.អ. |
| ២- | ឧ.សិ.កេតុ ថូរ និង ឧ.សិ.ស្វាយ សិត ព្រមទាំងបុត្រធីតា ... | ស.រ.អ. |
| ៣- | ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៤- | ឧ.សិ.គង់ ជាសត្ថា និង ស្វាមី ព្រមទាំងបុត្រ .................. | ស.រ.អ. |
| ៥- | ឧ.សិ.គុជ ឡាំងអេង និង អ្នកស្រី សេង យុវធា + កូនចៅ .. | ស.រ.អ. |
| ៦- | ឧ.ស.គៀង សេរីគង់ និង ឧ.សិ.តាន់ វ៉ានី ព្រមទាំងកូនចៅ . | ស.រ.អ. |
